វិទូដែលសំងំស្តាប់បណ្តើរ ពិចារណាបណ្តើរនោះក៏លូកមាត់ពោលសួរភ្លាមដែរ៖

-ប៉ុន្តែ កន្លងទៅជាងបួនឆ្នាំហើយ ម៉េចក៏ឯងទើបនឹងមករកជីកខ្សែកក្នុងពេលនេះ?

ជនល្មើសវ័យចំណាស់នោះ ឆ្លើយតបដោយមិនហ៊ានងើបមុខ៖

-មកពីថ្មីៗនេះ ខ្ញុំជួបប្រទះការលំបាកលំបិនខ្វះខាតពេក ក៏ស្រាប់នឹកឃើញដល់រឿងខ្សែក នោះទៅ។

វិទូងក់ក្បាលផ្ញក់ៗ ទំនងជាទទួលយកពាក្យចម្លើយនេះ ប៉ុន្តែភ្លាមនោះអ្នកកំលោះឮជនល្មើស ពោលបន្ថែម៖

-ខ្ញុំនិយាយការពិតអស់ហើយ សូមដោះលែងខ្ញុំទៅ! ពេលក្រោយខ្ញុំមិនហ៊ានឡើងទៅផ្ទះនោះ ទៀតទេ!

វិទូងាកសម្លឹងមុខជនល្មើស អ្នកពោលប្រាប់៖

-ឯងនិយាយរួចហើយមែន! ប៉ុន្តែពិតឬមិនពិត នៅមិនទាន់ដឹងច្បាស់នៅឡើយទេ! ឯងត្រូវរង់ចាំទម្រាំដល់ការពិតត្រូវបានបញ្ជាក់ទើបបាន!

ពេលចប់អ្នកកំលោះបែរខ្លួនដើរចេញទៅក្រៅ ប៉ូលិសប៉ុន្មានអ្នកដែលជាក្រុមសួរចម្លើយដែរ នោះក៏ដើរចេញទៅតាមពីក្រោយដែរ។

មកដល់ខាងក្រៅ វិទូនិយាយទៅកាន់ប៉ូលិសក្រោម៖

-បន្លាយពេលពីរបីម៉ោងទៀត សឹមដោះលែងពីរនាក់ហ្នឹងចេញ តែកុំឲ្យដាច់ឆ្ងាយពីភ្នែក ឲ្យសោះ!ខ្ញុំចង់ដឹងថា មានអ្នកណាខ្លះទាក់ទងជាមួយពួកវា!

ប៉ូលិសនោះឆ្លើយបាទ រួចដៀងភ្នែកមើលទៅកាន់បន្ទប់ខាងក្នុងដែលជនល្មើសទាំងពីរកំពុង អង្គុយត្របោមជង្គង់។ សំឡេងវិទូលាន់មកវិញបន្ត៖

-ទីពីរ យកកំណាកដីជាប់នឹងឆ្អឹងសពទៅឲ្យដុកទ័រសោភ័ណនៅខាងការិយាល័យវិភាគវេជ្ជសាស្ត្រពិនិត្យជាបន្ទាន់!

វគ្គទី៩

ភីណាប្រើគ្រឿងញៀន?

ដីកំពុងត្រូវជញ្ជូនចេញបណ្តើរៗពីក្នុងផើងផ្កា វិទូជាមួយអ្នករួមការងារតាមដានសម្លឹងយ៉ាងពិនិត្យពិច័យទៅកាន់ផើងផ្កាដោយអារម្មណ៍យ៉ាងចម្លែក។ អ្នកកំលោះងាកសម្លឹងទៅខាងឆ្វេងដៃបានឃើញរានហាលនៃបន្ទប់នោះនៅជាប់គ្នាជាមួយបន្ទប់នេះដូចសម្ដីជនល្មើសចំណាស់រៀបរាប់មែន ហេតុនេះកាលដែលគាត់នោះនិយាយថាខ្លួនបានឈរលបមើលពីទីនោះមក ក៏ដូចជាសមហេតុសមផលដែរ។

អ្នកសម្លឹងទៅផើងផ្កាដែលធំលាតសន្ធឹងកាត់ទទឹងផ្ទៃរានហាល ដីដែលជញ្ជូនចេញមកនោះកាន់តែច្រើនទៅៗហើយ បញ្ជាក់ថាផើងថ្មនោះធំមិនស្មើរទេ កាលដែលលួចលាក់កប់សាកសពមួយក្នុងនេះ គឺគ្មានបញ្ហាទាល់តែសោះ។

ខណៈដែលកំពុងជីកដីលាន់មកយ៉ាងរហ័សរបៀបភ្ញាក់ផ្អើលៈ

-ទាំងអស់គ្នាមកមើលនេះ!

វិទូក៏ដូចមិត្តរួមការងារទាំងអស់ដែរសុទ្ធតែស្ទុះយ៉ាងរហ័សមកក្បែរផើងថ្ម ដោយចោលភ្នែកសម្លឹងទៅក្នុងនោះ ដោយអារម្មណ៍ពោរពេញទៅដោយក្តីសង្ស័យ អស្ចារ្យពោរពេញទៅដោយក្តីសង្ស័យ អស្ចារ្យណាស់ខាងក្នុងផើងថ្មជម្រៅប្រមាណជិតមួយម៉ែត្រប៉ុណ្ណោះ ពិតជាមានបន្សល់នូវគម្រោងឆ្អឹងមនុស្សពិតៗមានទាំងជះមកនូវក្លិនដ៏គំរង់ផង។

វិទូងាកមុខចេញទាំងចិត្តច្របូកច្របល់ អ្នកមិនស្មានដល់ទាល់តែសោះថា ទីនេះបែរជាបន្សល់នូវវត្ថុបែបនេះសោះ ចំជាគេហដ្ឋានមិនធម្មតាមែន។

ភ្លាមនោះ អ្នកកំលោះនឹកដល់សម្ដីរបស់ក្មេងស្រីឯតៀមលក់អាហារពិសេសសម្ដីភីណាដែលជារឿយៗរំលឹកថាផ្ទះនេះមានខ្មោច តឡូវ ពិតជាមានមនុស្សស្លាប់កប់សាកសពចោលនៅទីនេះមែន ឬមួយថាពាក្យដែលថាផ្ទះនេះមានខ្មោចលង ក៏គឺជាការពិត?

ឆ្អឹងសាកសពត្រូវបានលើកចេញមក បន្ទាប់មកខ្សែកពេជ្រមួយខ្សែក៏ត្រូវបានរកឃើញដែរ បញ្ជាក់ថាសម្ដីទាំងប៉ុន្មានដែលជនល្មើសវ័យចំណាស់បានរៀបរាប់ឯប៉ុស្តិ៍ប៉ូលិស គឺសុទ្ធសឹងតែជាការពិតទាំងអស់។ បើអញ្ចឹងជនឃោរឃៅពីរនាក់ប្តីប្រពន្ធដែលបានសម្លាប់មនុស្សហើយរត់យករួចខ្លួននោះ ក៏មិនដឹងជាទៅដល់ណាហើយដែរ។

សំឡេងខ្សឹបខ្សៀវគ្នាមួយលាន់មកពីក្រោយខ្នងឮយ៉ាងច្បាស់នឹងត្រចៀកវិទូ៖

-អូ! អញ្ចឹងទេតើ បានជាអ្នកជុំវិញទីនោះនាំគ្នានិយាយថាផ្ទះនេះមានខ្មោចលង តាមមើលប្រាកដជាមានមែនហើយ! យកខ្មោចមកកប់ចោលរបៀបនេះ រឿងអីថា វាមិនលងនោះ?

អ្នកកំលោះវិទូស្តាប់សម្តីពួកគេបណ្តើរ ដៀងភ្នែកសម្លឹងទៅឆ្អឹងសាកសពដែលកំពុងត្រូវរៀបចំយកចេញទៅបណ្តើរ គំនិតសង្ស័យកំពុងចាក់ស្រេះក្នុងចិត្តអ្នក? កាលដែលភីណាមានកាយវិការមិនធម្មតា ហើយក្នុងផ្ទះតែងកើតមានរឿងមិនចេះអស់មិនចេះហើយយ៉ាងនេះ ក៏គួរឲ្យវិទូពិចារណាដែរ!

អ្នកកំលោះត្រឡប់មកផ្ទះវិញ គេរិះគិតមិនអស់មិនហើយពីរឿងនោះ បើតាមសម្តីជនល្មើសដែលសារភាព គឺថាពីរនាក់ធ្លាប់បានលួចឡើងមករកខ្សែក មុននេះម្តងរួចមកហើយ ប៉ុន្តែត្រូវម្ចាស់ផ្ទះឃើញទាន់ហេតុនេះពួកគេក៏មិនបានសម្រេចវាដូចគ្នាទៅនឹងសម្តីភីណា ដែលនិយាយថាយប់នោះនាងនិងបងថ្លៃនៅផ្ទះតែពីរនាក់ បន្ទាប់មកឮសំឡេងចម្លែកឯជាន់ខាងលើក៏នាំគ្នាឡើងទៅមើល ក្រោយមកបានប្រទះមនុស្សចម្លែកពីរនាក់កាន់ពូថៅនៅនឹងដៃឈរឯរានហាលខាងមុខបន្ទប់វត្ថុបុរាណ អញ្ចឹងហើយនាងនិងបងថ្លៃភ័យណាស់ក៏ប្រញាប់រត់ចុះមកក្រោម នាងថែមទាំងបានបញ្ជាក់ទៀតថា ពេលនាំគ្នារត់នោះហើយដែលបងថ្លៃនាងត្រូវទាក់ជើងដួលយ៉ាងដំណំរហូតដល់ដាច់ខ្យល់ស្លាប់ ប៉ុន្តែក្រោយមកក៏ស្រាប់តែឃើញបងថ្លៃនាងនៅរស់រានដូចធម្មតាវិញ? បើមែន តើរឿងស្រីអ្នកបម្រើត្រូវគេសម្លាប់កប់ក្នុងជើងថ្ម និងរឿងបងថ្លៃរបស់ភីណាមានទាក់ទងគ្នាដែរឬទេ?

ភ្លាមនោះដែរ ចិត្តមួយក៏ស្រាប់តែនឹកភ្លែតដល់រឿងចម្លែកកាលពីយប់ដែលអ្នកបានចូលទៅផ្ទះភីណាតែម្នាក់ឯង គាត់ក៏នៅសុខៗស្រាប់តែឮសូរមានសំឡេងមនុស្សស្រីយំត្អូញត្អែរមកពីជាន់ខាងលើ លុះដល់ឡើងទៅមើល សម្លឹងនោះបែរជាម្តងឮម្តងបាត់ ហើយរឿងដែលធ្វើឲ្យវិទូនឹកឡើងញាប់ញ័រក្នុងចិត្តនោះគឺថាសំឡេងនោះបានលាន់ចេញមកពីក្នុងបន្ទប់វត្ថុបុរាណហើយណាមួយយប់នោះវិទូក៏បានចូលទៅមើលក្នុងបន្ទប់នោះភ្លាមដែរ ប៉ុន្តែបែរជាគ្មានអ្នកណាម្នាក់ទាល់តែសោះ អ្នកមានទាំងឈរនៅនឹងមុខរានហាលក្បែរជើងថ្មនោះផង ប៉ុន្តែមិននឹកដល់ថាក្នុងនោះមានសាកសពមនុស្សទាល់តែសោះឡើយ ឬមួយថាយប់នោះឯងដែលអ្នកកំលោះត្រូវខ្មោចលង?

ថ្ងៃបន្ទាប់វិទូទៅពេទ្យរកភីណាតាំងតែពីព្រលឹមតាមពិត គឺបណ្ដាលពីរឿងគាត់ឃើញឆ្អឹងខ្មោចក្នុងជើងថ្មផ្ទះនោះធ្វើឲ្យអ្នកកំលោះកាន់តែនឹកអាណិតនាង។

អ្នកកំលោះចុះមកជួបអ្នកអួនក្នុងបន្ទប់ទទួលភ្ញៀវភ្លាមក៏ឮគាត់ពោលសួរភ្លាមដែរ៖

-លោកក្មួយ! រឿងហេតុយ៉ាងម៉េចខ្លះ? ម៉េចក៏ ម៉េចក៏ ក្នុងផ្ទះមានសាកសពទៅវិញ?

គ្រាន់តែឃើញទឹកមុខខ្វល់ខ្វាយរបស់គាត់ក៏អ្នកដឹងថាគាត់កំពុងត្រូវភាពភ័យរន្ធត់គ្របសង្កត់ក្នុងចិត្តដែរ អ្នកប្រឹងពោលលួងលោម៖

-លែងអីហើយ! ប៉ូលិសយកចេញអស់ហើយ មីងឈប់ភ័យទៅ!

ស្ត្រីនោះហាក់មិនបានធូរស្រាលក្នុងចិត្តសោះ គាត់នៅតែបង្ហាញទឹកមុខខ្វល់ខ្វាយដដែលដោយរអ៊ូតែម្នាក់ឯង៖

-ផ្ទះនោះមិនស្រួលមែន អ្នកនាងតូចកាលនៅដឹងខ្លួនក៏បាននិយាយប្រាប់មីងរហូតដែរថា ផ្ទះនោះមានខ្មោចតែមីងចេះតែគិតថាអ្នកនាងឈឺពេក ក៏រវើរវាយផ្ដេសផ្ដាស!

កំលោះងាកទៅរកនារីគូស្នេហ៍ដែលនៅតែបិទភ្នែកជិតឈឹងដោយសារនាងនៅមិនទាន់មានស្មារតីល្អវិញទេ។ អ្នកកំលោះពោលសួរមួយៗមកកាន់ស្ត្រីចំណាស់ដែលនៅមានក្ដីបារម្ភលើផ្ទៃមុខនៅឡើយ៖

-ភីណាធ្លាប់ប្រាប់មីងថាម៉េចខ្លះ?

គាត់ក្រឡាប់គ្រាប់ភ្នែកភិតភ័យរួចទើបស្រដីតាមត្រង់ថា៖

-ពេលខ្ញុំចូលទៅបត់ខោអាវរៀបចំបន្ទប់ជូនអ្នកនាង អ្នកនាងនិយាយថា ម្ចាស់ផ្ទះមុនបានសម្លាប់ស្រីអ្នកបម្រើក្នុងផ្ទះយើងដែរ តែខ្ញុំស្ដាប់ហើយគិតថាអាចថាគេជិតខាងកុហកអ្នកនាងលេងព្រោះឃើញអ្នកនាងត្រង់! ដឹងអីថាមិនត្រឹមសម្លាប់ចោលក្នុងផ្ទះប៉ុណ្ណឹងទេ ថែមទាំងកប់សាកសពក្នុងផ្ទះទៀត ហួសហេតុដល់ហើយ!

វិទូស្ដាប់សម្ដីស្ត្រីចំណាស់បណ្ដើរ អ្នកកំលោះផុសក្ដីងឿងឆ្ងល់ក្នុងចិត្តបណ្ដើរ អ្នកកំលោះក៏បន្លឺសួរភ្លាមដែរ៖

-អ្នកជិតខាងណាដែលដឹងរឿងដែលម្ចាស់ផ្ទះមុនគេសម្លាប់ស្រីបម្រើ? ហើយយកមកនិយាយប្រាប់ភីណា?

ស្ត្រីអ្នកបម្រើជ្រប់មុខដោយទឹកមុខព្រួយបារម្ភមិនទាន់រសាយ។ គាត់ឆ្លើយតប៖

-ខ្ញុំ....ខ្ញុំអត់បានសួរដែរ.....

វិទូដៀងភ្នែករិះគិត៖

"ឬមួយក៏...ប្រុសស្រីពីរ នាក់បងប្អូននោះ?"

អ្នកកំលោះងើបមុខទៅរកស្ត្រីអ្នកបម្រើដែលកំពុងឈោងដណ្តប់ភួយឲ្យនារីរូបល្អ គេពោលសួរទៀត៖

-មីងអ្ហា!ចុះក្មេងស្រីប្រុសពីរនាក់នៅជាប់ផ្ទះយើងនោះ ភីណាស្គាល់គេតាំងអីពេលណាមក!?

ស្ត្រីធ្វើភ្នែកឡិងឡង់ជាសញ្ញាថាគាត់ក៏មិនដឹងដែរ។

មិនទាន់ហើបមាត់សួរបន្ថែមផង ស្នូរទូរសព្ទរោទ៍ឡើងធ្វើឲ្យវិទូត្រូវចាកចេញទៅស្តាប់នៅខាងក្រៅ៖

-អាឡូ! ភ័ណ!?

សំឡេងពីចុងម្ខាងលាន់មកត្រហេបត្រហប៖

-ទូអ្ហា!ដូចស្មានអញ្ចឹង រឿងខ្មោចក្នុងផើងផ្កានោះ ក្លែងក្លាយទេ!

នាយប៉ូលិសក្របួចមាត់ស្តាប់សេចក្តីរាយការណ៍បន្តដោយអារម្មណ៍ក្តុកក្តួលក្នុងចិត្ត សំឡេងពីចុងម្ខាងពោលមកបន្ថែម៖

-ឆ្អឹងនោះជាឆ្អឹងអ្នកស្លាប់បួនប្រាំឆ្នាំមកហើយមែន ប៉ុន្តែវាមានលាយឡំជាមួយដីមានជាតិសំណខ្ពស់ដែលគួរតែត្រូវបានគេកប់ក្នុងតំបន់ក្បែរសមុទ្រ មិនមែនកប់នៅក្នុងផើងផ្កានោះទេ!

វិទូជ្រួញចិញ្ចើម។ កែវភ្នែកដែលបង្ហាញថាមានចម្លើយមួយចំនួនបានអណ្តែតមកតបនឹងការស្មុគស្មាញច្រើនថ្ងៃមកហើយនេះរុញឲ្យអ្នកកំលោះជះសំណួរទៅវិញជាបន្ទាន់៖

-គេបង្កើតរឿងនេះឡើងក្នុងគោលបំណងអ្វី?

វេជ្ជបណ្ឌិតភ័ណមិនឆ្លើយតបនឹងសំណួរគូកនតែគេបែរជានិយាយពន្យល់បន្ថែម៖

-ផ្កាកុលាបដែលផ្សាំដោយសារធាតុគីមីគឺគេអាចដាំវាក្នុងរវាងពី៣ទៅ៥អាទិត្យឲ្យស្រស់បំព្រងបាន តែបើថាចង់ដកវាឡើងហើយកប់ឆ្អឹងចូលទៅក្នុងហ្នឹង ក៏អាចរក្សាជីវិតវាបានដោយគ្រាន់តែគេដាក់សារធាតុម្យ៉ាងដែលគេប្រើលើទីផ្សារវេជ្ជសាស្ត្រខុសច្បាប់ឈ្មោះថា3Mជាអក្សរកាត់នៃពាក្យថាMagic Matrixyl Metal។ របស់នេះក៏មាននៅលាយឡំជាមួយដីនោះដែរ។ ដែលសំខាន់គឺសារធាតុ នេះអត់ដែលឃើញមាននៅស្រុកខ្មែរទេពីមុនមក។ តាមរយៈសារធាតុនេះ ឯងប្រហែលជាអាចរកអ្នកដែលដាក់គម្រោងឆ្អឹងសពទៅបន្លំក្នុងផើងនោះឃើញ។ ចំណែកគេធ្វើអញ្ចឹងដើម្បីអី ឯងសួរខ្ញុំ ខ្ញុំម៉េចនឹងដឹង? នែខ្ញុំកំពុងផ្ញើរឯកសារ3Mទៅmailឯង! Fileវាងធំបន្តិចប្រហែលត្រូវស៊ីពេលដែរ!អត់ផ្ទុត់សិនទៅ!

វិទូតបវិញយ៉ាងរហ័ស៖

-ដឹងហើយ! អរគុណណាស់ភ័ណ!

បុរសឈ្មោកសម្លឹងទៅបរិវេណខាងក្រោមនៃមន្ទីរពេទ្យដោយអារម្មណ៍តានតឹង។ ស្ថានភាពធ្វើឲ្យគេស្រាប់តែនឹកឃើញទៅដល់រឿងសំខាន់អ្វីមួយ។ កំលោះប៉ូលិសចុចទូរសព្ទហើយនិយាយ៖

-អាឡូ! លោកបង! ខ្ញុំសុំអនុញ្ញាតដាក់កម្លាំងនៅពេទ្យមើលភីណាឲ្យបានតឹងតែងបន្តិច!

សំឡេងលោកកុសលឆ្លើយតបពីចុងម្ខាង៖

-បាន! បងក៏មិនសូវទុកចិត្តដែរ! តែសំខាន់បងចង់យកនាងមកផ្ទះឲ្យបានឆាប់កាន់តែល្អ!

វិទូមិនចេញស្ដីតែនាយរិះគិតម្នាក់ឯង៖

"នាងមិនគួរទៅកាន់ទីនោះវិញទេមុនពេលខ្ញុំរកឃើញការពិតទាក់ទងនឹងផើងផ្កានោះ"

គេជម្រាបលាអនាគតបងថ្លៃហើយបិទទូរសព្ទគាប់ជួនស្ត្រីអ្នកបម្រើរត់មកអរកខិបកខុប៖

-លោកក្មួយនាងតូចភ្ញាក់ហើយ! ឥឡូវ ទាររកបបរ ខ្ញុំរត់ទៅទិញសិន!

វិទូអរភើតពេលលឺថានាងក្រមុំចេះនឹកឃ្លានព្រោះមួយយប់មួយថ្ងៃមកហើយនាងគេងស្ងៀមគ្មានកម្លាំងកំហែងសួរអ្វីក៏គ្រវីក្បាលនិងធ្វើមុខស្លេកស្លាំង។ អ្នកកំលោះរវៀសរវៃដើរចូលទៅក្នុងបន្ទប់ជាមួយសម្ដីពោលប្រាប់អ្នកអូនថា៖

-មីងទៅចុះ! រកផ្លែឈើល្អៗមកផង!

អ្នកកំលោះចូលទៅរកគូស្នេហ៍ដែលបើកភ្នែកប្រឹមៗសម្លឹងមកនាយ។ ឃើញនាយកាលណានាងរលើងរលោងរកកលនឹងយំ។ វិទូប្រឹងញញឹមលួងចិត្តដោយចូលទៅអង្គុយក្បែរនាងលើកដៃនាងមកកាន់ថ្នមៗផង។

-អូនចង់ទៅផ្ទះ!

នេះជាសម្ដីដំបូងដែលនារីនិយាយមកកាន់នាយខ្សោយៗបន្ទាប់ពីនាងខ្លួនឯងជាអ្នកចាកចេញពីផ្ទះហើយទៅរស់នៅApartmentស្ងាត់ជ្រងំរហូតដល់មានរឿងកើតឡើង។ នាងច្រត់ដៃក្រោកអង្គុយផ្អែកខ្នងនឹងជញ្ជាំង អ្នកកំលោះក៏ជួយនាងហើយនិយាយថ្នមៗទៅកាន់នាង៖

-អូនមកនៅផ្ទះបងវិញទៅម៉េចដែរ!

នាងក្រមុំងាកសម្លឹងមុខគេភ្លាម កាលបើឮសម្ដីនេះ នាងបញ្ចេញអាការហួសចិត្ត ដោយបន្លឺ៖

-និយាយអញ្ចឹងទៅកើតដែរ?

វិទូយល់ចិត្តតរុណីគូស្នេហ៍ថានាងគិតឃើញយ៉ាងណាទៅហើយ ក៏ប៉ុន្តែអ្នកកំលោះនៅតែព្យាយាមរើសយកពាក្យសម្ដីដែលចេញពីទឹកចិត្តពិតៗនិយាយទៅរកនាង៖

-មុនក្រោយគង់តែរៀបការជាមួយបងហ្នឹង បើនៅផ្ទះនោះមិនសប្បាយចិត្ត បងមានតែយកអូនទៅនៅក្បែរបង! បើមិនអញ្ចឹង ឬខ្លាចបងកុសលមិនព្រម ចាំបងរើទៅនៅក្បែរអូនវិញក៏បាន!

នាងក្រមុំសម្លឹងមុខនាយបន្តិច រួចដកក្រសែភ្នែកចេញលែងមើលមុខគេ នាងពោល៖

-វិទូ! អូនកំពុងខ្វល់ខ្វាយណាស់ គ្មានចិត្តនឹងនិយាយលេងសើចទេ!

វិទូសម្លឹងទៅស្រីស្រស់ដែលបិទភ្នែកលែងចេញស្ដី អ្នកសម្លឹងទៅម្រាមទាំងប្រាំដែលទន់ល្វក់ ហើយត្រជាក់ស្រិបក្នុងប្រអប់ដៃខ្លួនស្រាប់តែចេញចំហាយក្ដៅអ៊ុនៗ អ្នកកំលោះដឹងថានាង អៀនក៏ បន្តពោលស្រាលៗក្បែរសោតានាង៖

-បើពិបាកពេកយើងរៀបការឲ្យហើយទៅ?

នាងក្រមុំនៅរក្សាការស្ងាត់ស្ងៀមរបស់ខ្លួនបានបន្តិចទើបឆ្លើយតបតិចៗ៖

-ទោះជាចង់រៀបការ ក៏មិនត្រូវមកសួរខ្ញុំដែរ!

វិទូញាក់ស្មាញញឹមស្រស់ អ្នកឈ្ងោកសម្លឹងតាមដែលនាងឱនមុខ អ្នកពោលតប៖

-ត្រូវតែសួរអូនអញ្ចឹងហើយ ព្រោះបងចង់រៀបការជាមួយអូន! ឯបងកុសល បងដឹងថា គាត់ មិនជំទាស់ទេ តែបើគាត់ជំទាស់ក៏បងមិនខ្លាចដែរ ឲ្យតែភីណាឆ្លើយថាព្រមបានស្រេចទៅ ហើយ!

ភីណាញញឹមបន្លឺវាចាទាំងគិតមិនងើបមុខ៖

-បានតែមាត់ទេ!

វិទូញញឹមកាលបើឃើញអាការរបស់ក្រមុំគួស្នេហ៍ អ្នកពោលទៅកាន់នាង៖

-ម៉េចក៏ដឹងថាបងបានតែមាត់? រៀបការនឹងបងទៅ មិនចាំបាច់ទៅនៅផ្ទះនោះវិញទេ ហើយក៏ មិនបាច់ភ័យខ្លាចរាល់ថ្ងៃដែរ! យល់ព្រមធ្វើប្រពន្ធបងដែរអត់?

ភីណាពោលតបវិញដោយឈ្ងោកមុខជាប់ដដែល៖

-ប្រពន្ធអីទៅ? ខ្ញុំមិនចេះធ្វើម្ហូបឲ្យបងឯងហូបទេ!

វិទូគ្រវីក្បាលឆ្លើយតបដោយញញឹម៖

-អាហារអន់យ៉ាងណាក៏បងព្រមញ៉ាំដែរ!

ភីណានៅតែពោលបន្ថែម៖

-ហើយអូនប៉ុនខឹងទៀត!

-មានអី! បងចូលចិត្តលួងលោមគេណាស់! ពេលណាអូនខឹង ចាំបងជាអ្នកលួងចុះ!

ភីណាងើបមុខដែលញញឹមដោយអាការអៀនប្រៀនសម្លឹងមកអ្នកកំលោះ នាងសម្លក់ដោយគ្នាន់ក្នាញ់ ហើយឧទានៈ

-ចុះពេលមុន បងក្រែងថាសរសៃប្រសាទអូនមានបញ្ហានោះអី? បងសុខចិត្តរៀបការជាមួយអ្នកសរសៃប្រសាទមានបញ្ហាបែបនេះដែរអ្ហេស៎!

វិទូញញឹមស្រស់ អ្នកឆ្លើយតបដោយសម្លឹងមុខនារីគូស្នេហ៍មិនដាក់ភ្នែកៈ

-បើអូនមានបញ្ហាសរសៃប្រសាទ បងសុខចិត្តវិកលចរិតដែរទៅចុះ នឹងបាននៅជិតអូន!

ភីណាឈ្ងោកមុខបង្ហាញអាការគ្នាន់ក្នាញ់ នាងឧទានតិចៗៈ

-សម្តីផ្អែម គួរឲ្យស្អប់ណាស់!

តាមពិតវត្ថុបំណងសំខាន់ក្នុងពេលនេះគឺវិទូត្រូវការនាំភីណាចេញពីផ្ទះនោះបណ្តោះអាសន្នសិន ហើយគេគួររកហេតុផលឲ្យបានសមស្របជាជាងប្រាប់នាងថាផ្ទះនោះមានគ្រោងឆ្អឹង និងមានគេណា ម្នាក់នៅទីងងឹតរចនាសេណារីយោនេះឡើងយ៉ាងអាថ៌កំបាំង ប៉ុន្តែមិនទាន់ដឹងថាវានោះជាអ្នកណាហើយអ្វីទៅជាបំណងពិតរបស់វា។

នៅពេលស្រីស្អាតរសាយពីអារម្មណ៍តប់ប្រមល់និងខ្វល់ខ្វាយដោយសារសម្តីលួងលោមមុននេះ របស់ខ្លួន ទើបប៉ូលិសវ័យក្មេងចូលដល់សាច់រឿង។ គេនិយាយសួរតិចៗទៅកាន់ភីណាដែលកំពុង ចុចទូរសព្ទៈ

-អូនដឹងរឿងស្រីអ្នកបម្រើត្រូវគេសម្លាប់ក្នុងផ្ទះកាលពីបួនឆ្នាំមុនដែរអត់?

ភីណាបើកភ្នែកធំៗ។ នាងងើបមុខយ៉ាងរហ័សសម្លឹងគូដណ្តឹងសញ្ជឹងថាហេតុអ្វីគេដឹងរឿងនេះដែរ។ តែបុរសពោលសួរនាងបន្ថែមមុនពេលនាងឆ្លើយនឹងសំណួរគេទៅទៀតៈ

-អ្នកណាជាអ្នកដឹងរឿងនេះហើយនិយាយប្រាប់អូន!

នាងមិនតបព្រោះតក់ស្លុត។ ពេលអារម្មណ៍ទើបតែបានល្អបន្តិចស្រាប់តែចិត្តផ្តើមនឹកឃើញដល់រឿងតំណាលដ៏គួរឲ្យស្ញើបនោះសាជាថ្មី គួបផ្សំនឹងឥទ្ធិពលគ្រឿងស្រវឹងផ្តោតអារម្មណ៍

ទៅដែលមិនទាន់បន្សាបបាន១០០ភាគរយផងបេះដូងភីណាទៅជាលោតញាប់។ វិទូខំស្រវា អោបនាងដើម្បីជួយទប់ស្កាត់ការរំជួលចិត្តៈ

-បាន! អត់និយាយក៏មិនអីដែរ! មិនអីទេ! បងសួរលេងៗប៉ុណ្ណឹង!

មិនស្មានដល់ថាភីណាស្រាប់តែហុចទូរសព្ទមកឲ្យអ្នកកំលោះ ដោយមានឈ្មោះនេត្រនៅពីលើអេក្រង់នោះ។ តាមពិតនាងកំពុងចុចទៅរកនារីនិស្សិតនៅក្បែរផ្ទះគាប់ជួនលឺវិទូពោលសួរនាងទៅជារន្ធត់ហើយគាំងឆ្លើយមិនរួច ក៏ហុចទូរសព្ទមកឲ្យគូស្នេហ៍ជាចម្លើយជំនួសវិញ។ វិទូមើលឃើញកាលណាគេសង្ហើញសួរដោយបើកភ្នែកមូលក្លុំៈ

-បងប្អូនពីរនាក់ហ្នឹងជាអ្នកប្រាប់អូន?

ភីណាងក់ក្បាលផ្ងក់ៗជំនួសចម្លើយធ្វើឲ្យវិទូរវេភ្នែកសញ្ជឹងគិត។ សំឡេងក្មេងប្រុសរបស់ស្ត្រីជានិស្សិតនោះលាន់មកក្នុងសោតាអ្នកហាក់នៅថ្មីៗៈ

"ដំបូងខ្ញុំចេញមកក្រៅទន្ទេញមេរៀន ក៏ស្រាប់តែឮស្ងរសំឡេងដូចមិនធម្មតា ក៏ឡើងលើរានហាលសម្លឹងមើលមកផ្ទះជាប់គ្នានេះ ខ្ញុំឃើញពីរនាក់នោះកំពុងកាន់ពូថៅម្នាក់មួយឈររេរាមុខបន្ទប់ ខ្ញុំភ័យណាស់ក៏រត់ទៅរកប៉ូលិសភ្លាមទៅ។"

គេងើបមុខមករកគូស្នេហ៍ដែលនៅតែសម្លឹងអ្នកដោយក្រសែភ្នែកព្រួយខ្វល់។ អ្នកកំលោះសួរនាងស្រាលៗថាៈ

-ភីណា! អត់អីទេ! កុំភ័យណ៎ា! បងគ្រាន់តែមានរឿងខ្លះមិនសូវយល់! បងសួរធម្មតាៗ បើដឹងចាំឆ្លើយបើអត់ក៏ហីទៅ! អូខេ!

នារីងក់ក្បាលតិចៗហាក់កក់ក្ដៅចំពោះពាក្យពន្យល់របស់វិទូ គេក៏សួរបន្តៈ

-អូនស្គាល់បងប្អូនពីរនាក់នោះយូរប៉ុណ្ណាហើយ?

នារីនៅទីទើរព្រោះមិនដឹងត្រូវឆ្លើយយ៉ាងណា វិទូចាប់ប្រើចិត្តសាស្ត្រសួរចម្លើយរបស់នាយៈ

-គឺបងចង់ដឹងថាអូនជួបពួកគេសរុបប៉ុន្មានដងហើយ?

-គឺជួបនៅផ្ទះយើងម្ដង នៅផ្ទះគេម្ដងដែលអូនទៅជាមួយបងនោះ!

វិទូនិយាយកាត់៖

- ចុះកាលជួបនៅផ្ទះយើង គេមានធុរៈអីដែរ? គេស្គាល់អ្នកណាខ្លះនៅផ្ទះយើង?

- គេមកថតខ្មោច!

ភាគទី១៩

វិទូ ជ្រួញចិញ្ចើមហួសវិស័យនឹងជឿត្រចៀកខ្លួន។ គេសួរបកតិចៗ៖

– ស្អីគេភីណា?

ស្រីស្រស់បានជ្រុលរបូតមាត់ទៅហើយ លុះដល់ឮវិទូបន្លឺសួរយ៉ាងនោះទៀត នាងនៅស្ងៀមមិនទាន់ហើបមាត់ឆ្លើយតបថាយ៉ាងណានៅឡើយ ដោយកំពុងរិះគិតថា មិនដឹងត្រូវបដិសេធបង្វែររឿងឬក៏យ៉ាងណាទេ ខណៈដែលវិទូពោលសួរមកសាជាថ្មី៖

- ម៉េចក៏សួរទៅលែងមាត់ហើយ?

ភីណានៅស្ងៀមបន្តិច ទើបពោលតប៖

-ខ្ញុំអត់ចង់និយាយទេ ព្រោះគង់តែបងឯងមិនជឿ!

វិទូបិទភ្នែកនិយាយលួងនាង៖

-ឲ្យតែជាការពិត!ឆាប់និយាយទៅ!

ភីណាងក់ក្បាលហើយចាប់ផ្ដើមនិយាយតិចៗទាំងក្ដាប់ដៃបុរសណែនជាងមុន៖

-ពីរនាក់បងប្អូនគេលួចផ្លោះចូលមកតាមដំបូលផ្ទះតាមរានហាលខាងលើបន្ទប់ហើយចុះតាមជណ្ដើរមកជាន់ទីមួយ កាលណោះគឺយប់ជ្រៅដែរហើយ ផ្ទះស្ងាត់ច្រៀប គេយកមកជាមួយម៉ាស៊ីនថតនិងTabមួយម្នាក់ផងហើយក៏វាក់អ៊ើនឹងខ្ញុំ ….

តាមពិតគឺវិទូកំពុងហួសចិត្ត ឮិតអីកណ្ដាលអធ្រាត្របងប្អូនពីរនាក់ លួចផ្លោះរបងមកក្នុងគេហដ្ឋានហើយនាង នៅតែការពារជួយលាក់ពួកគេដល់ពេលនេះអ្នកនិយាយភ្លាម៖

-ហើយគេប្រាប់អូនថាទៅថតខ្មោចអូនក៏ជឿ?

នារីបួញមាត់ងក់ក្បាលផ្ងក់ៗ។ វិទូកាន់តែហួសចិត្តណាស់ទៅទៀត អ្នកកំលោះពោលសួរវិញ ៖

-ចុះម៉េចក៏ពីរនាក់បងប្អូននោះដឹងថាផ្ទះ អូនមានខ្មោច?

ភីណាបង្ហាញទឹកមុខម៉ត់ចត់ នាងសម្លឹងមកកាន់វិទូផង ឆ្លើយតបវិញផង៖

-បងឃើញហើយ? អ្នកជុំវិញនោះ អ្នកណាក៏ដឹងថាផ្ទះ...ផ្ទះអូនមានខ្មោចដែរ! ចំណែកនេត្រ និងប្អូនគេធ្លាប់ដឹងថាផ្ទះនោះមានគេស្លាប់តាំងពីបួនឆ្នាំមុនម្ល៉េះគឺអ្នកបម្រើរបស់ពួកគេឈ្មោះ មីងសានជាអ្នកនិយាយ!

វិទូភ្ញាក់បន្តិចដែរ៖

-មីងសាននៅឯណា?

-គាត់ស្លាប់ហើយ!? តែគាត់ជាអ្នកឃើញ គេសម្លាប់ស្រីអ្នកបម្រើឈ្មោះកែវផ្ទាល់ភ្នែក ហើយ គាត់និយាយប្រាប់នេត្រនិងប្អូនគេ!

វិទូងក់ក្បាលផ្ងក់ៗ ដោយទឹកមុខស្មើ ៖

-អញ្ចឹងបានអូនឯងខ្លាចផ្ទះម្ល៉ឹងៗ?

ស្តាប់លឺវិទូរអ៊ូទើបភីណាប្រញាប់ប្រញាល់បដិសេធ៖

-មានឯណា! កាលនោះនេត្រនិយាយរឿងទាំងអស់ប្រាប់ហើយក៏ខ្ញុំមិនទាន់ជឿទេ! តែខ្ញុំចាប់ ផ្តើមជឿថាផ្ទះយើងមានខ្មោច គឺនៅយប់បន្ទាប់!

វិទូសួរដោយសង្ស័យ៖

-ពីរនាក់នោះធ្វើម៉េចបានអូនឯងជឿ?

ភីណានិយាយទាំងក្រញ៉ូវ៖

-ខ្ញុំថាបើប្រាប់ហើយគ្មានអ្នកណាជឿទេ! ពេលនេះមកសួរធ្វើអី? គឺប្រពន្ធដ៏ល្អរបស់បង កុសលហ្នឹងហើយគេក្លាយជាខ្មោច គេនៅសំងំធីសាច់គោស្រស់នៅចង្ក្រានបាយ! ខ្ញុំឃើញ

ផ្ទាល់ភ្នែក! យប់នោះ បាននេត្រនិងប្អូនគេចូលមកម្ដងទៀត គេទាន់ខ្ញុំដែលកំពុងតក់ស្លុត! គេខ្ទប់មាត់ហើយគ្រាខ្ញុំស្ទាត់ៗឡើងមកបន្ទប់វិញ!

វិទូមិនអាចទប់ស្កាត់ចិត្តងឿងឆ្ងល់បានឡើយ អ្នកពោលសួរបន្ថែមភ្លាមៈ

-យប់នោះអូនឃើញអីក្នុងបន្ទប់បាយបានជាតក់ស្លុតដល់ម្ល៉ឹងៗ?

ភីណាបើកភ្នែកធំៗឆ្លើយតបមកកាន់វិទូវិញ៖

-ប្រាប់ហើយថាឃើញ...ឃើញខ្មោចឆៅណ៎ា! គឺអ្នកបងជាខ្មោចឆៅ!

វិទូភ្លាមនោះក៏នឹកដល់គ្រឿងញៀនដែលនៅផ្ទុកក្នុងខ្លួននាង។ ជានិច្ចកាលអ្នកកំលោះគិតថា គឺ សារធាតុអស់នោះហើយដែលធ្វើឲ្យនាងនិយាយស្ដីគ្មានហេតុផលរហូតមក។ ប៉ុន្តែហេតុអ្វីកន្លងមកច្រើនថ្ងៃហើយ នាងឈឺផងជាផង ក្រោកមកវិញនៅតែនិយាយរឿងដដែលៗអត់ផ្លាស់ប្ដូរ? ឬមួយថាអ្វីដែលនាងនិយាយវាជាការពិត ដែលនាងមិនអាចភ្លេចវាបាន?

អ្នកប្រឹងវិទូញញឹមតិចៗជាកិច្ចបង្កើនការទុកចិត្តឲ្យនាង ហើយនិយាយសួរបន្ត៖

-ថ្នាំនេះជារបស់អូនមែន អត់?

គេហុចកំប៉ុងថ្នាំទៅនាង។ ស្រីស្អាតបើកមើលកាលណាងក់ក្បាលទទួល។

"មើលទៅនាងដូចជាមិនដឹងថាថ្នាំនេះជាថ្នាំញៀនទេ! មានន័យថាមិនមែននាងលួចលាក់ប្រើវាឡើយ! វាមានតែអ្នកណាម្នាក់មានចេតនាឲ្យនាងប្រើ "គេគិតដោយញ័រទ្រូង។ បុរសចាប់សួរនារីបន្តភ្លាមៈ

-អូនបានថ្នាំអស់ហ្នឹងពីណាមក?

ភីណាអស់ពីបើកភ្នែកគ្រលួងនាងទៅជាសើចខឹក។

-បងឯងម៉េចហ្នឹង? ក្ដៅខ្លួនអត់? ថ្នាំនេះពីពេលចូលពេទ្យលើកមុន ពេទ្យឲ្យអូននោះអី? មកសួរចម្លើយសព្វ បើរឿងថ្នាំនៀក!? កាលពីនៅ Apartmentក៏យកមកសួរម្ដងហើយ!

វិទូនៅស្ងៀមភ្លឹកភ្លាំងស្មារតីដោយសារពេទ្យធ្លាប់បានបដិសេធហើយថានេះមិនមែនជាគ្រាប់ថ្នាំដែលគាត់ឲ្យទៅភីណាលេបព្យាបាលជំងឺឡើយ។ ស្ថានភាពនេះ១០០ភាគរយបញ្ជាក់ថា

មានគេដូរថ្នាំ។ តើគេជាអ្នកណា? អត់ទាន់សំខាន់ទេព្រោះរកមិនឃើញឡើយលើកលែងតែដឹងថាគេធ្វើនេះដើម្បីអ្វីសិន? វិទូដៀងភ្នែកសម្លឹងប្រអប់ថ្នាំដែលនៅក្នុងដៃ អ្នកកំលោះយល់ថាប្រសិនបើជននោះគ្រាន់តែកំណាចចង់ឲ្យភីណានៅត្រាំត្រែងក្នុងជំងឺ គេគ្រាន់តែដាក់ថ្នាំផ្សេងមកដើម្បីឲ្យនាងមិនអាចសះស្បើយចុះហេតុអ្វីគេចាំបាច់ប្រើថ្នាំញៀនប្រភេទរវើរវាយនេះ? មានតែគេគិតដល់ផែនការអ្វីផ្សេងពីនេះទៀត?

នាយប៉ូលិសវ័យក្មេងសម្លឹងផ្ទៃមុខរលើបរលោងរបស់ធីតាគួរស្នេហ៍ចំពោះមុខម្នាក់ឯងស្ងាត់ៗ "ម្នាក់នោះគួរតែនៅជិតស្និទ្ធនឹងភីណាណាស់ទើបអាចមានឱកាសប្ដូរថ្នាំនេះបាន"។

នាយនិយាយថ្នមៗទៅកាន់នាង៖

-បងយកថ្នាំនេះចោលហើយ! ព្រោះអូនលេបអត់ត្រូវ!

វគ្គទី១០

ការពិតនៅជិតបង្កើយ

មេឃងងឹតស្លុបផ្លូវក៏រអិលព្រិលដោយសំណល់ពីព្រះភិរុណ។ វិទូនិងក្រុមការងារធ្វើដំណើរញាប់ ស្មេរកាត់តាមភ្លឺស្រែនិងកូនព្រៃលិចទឹកទម្រាំដល់កូនភូមិតូចមួយក្បែរជើងភ្នំ ចំពេលថ្ងៃត្រង់ប៉ុន្តែព្រះអាទិត្យគ្មានកម្លាំងមកបំភ្លឺឲ្យមេឃស្រឡះល្អឡើយដោយសារដុំពពកខ្មៅ។

នៅក្នុងកូនផ្ទះឈើសង់ផ្ទាល់ដីមានតែសូរសំឡេងយំរអឹកតិចៗរបស់ស្រីពីរបីនាក់។

-លោកក្មួយគាត់កើតឃ្លង់អញ្ចឹងគ្មានអ្នកណាហ៊ានទទួលមើលថែគាត់ទេ មានតែខ្ញុំជាប្អូនយកគាត់មកទុកហ្នឹង! គាត់ធ្ងន់ណាស់ហើយ! អ្នកភូមិគិតថាឲ្យធម៌គាត់ល្ងាចនេះហើយ!

វិទូសម្លឹងមុខអ្នកឲ្យព័ត៌មានជាមួយសំណួរពីក្រោមម៉ាសបិទមុខ៖

-ឲ្យពួកខ្ញុំចូលមើលគាត់ផង!

-អញ្ជើញចុះលោកក្មួយ!

កំលោះប៉ូលិសនិងគ្នីគ្នាចូលទៅមួយសន្ទុះក៏ចេញមកវិញ។...

នៅពេលដែលស្បៃរាត្រីគ្របដណ្ដប់ជាថ្មីមកលើរាជធានីភ្នំពេញ វិទូបង្ហាញវត្តមាននៅក្នុងភោជនីយដ្ឋានក្បែរមន្ទីរពេទ្យដែលមានលោកកុសលនៅរង់ចាំជាស្រេច។

-លោកបង! មីងម៉ាប់គេចមិនផុតពីយប់នេះទេ! គាត់ឈឺធ្ងន់ពេក! ចេញដំបៅរលួយពេញខ្លួន! ពេទ្យមូលដ្ឋានដែលទៅជាមួយខ្ញុំប្រាប់ថាគ្រឿងក្នុងគាត់ខូចអស់ហើយ! ខ្ញុំធ្វើតាមលោកបងប្រាប់ បានជូនលុយកាក់ទាំងអស់នោះដល់ក្រុមគ្រួសារគាត់ហើយដែរ! ខ្ញុំប្រាប់ថាក្នុងផ្ទះមានរឿងលោកបងនៅរវល់ជាមួយភីណាខាតបង់ទាំងជំនួញទាំងការងារសង្គម អត់អាចទៅមើលគាត់ជាចុងក្រោយបាន អ្នកស្រុកក៏យល់ចិត្តហើយ! កុំពិបាកចិត្តអី!

លោកកុសលដកដង្ហើមធំគាត់និយាយតិចៗ៖

-ផ្ទះនោះមានរឿងច្រើនពេកហើយ បងគិតរើចេញទៅនៅកន្លែងផ្សេងវិញពេលភីណាចេញពីពេទ្យ!

-ទៅ Apartment បឹងកេងកងឬយ៉ាងម៉េច?

-អត់ទេ ប្រហែលទិញផ្ទះផ្សេងហើយដាក់ផ្ទះធំលក់ចោលវិញ!

វិទូងក់ក្បាលផ្ងក់ៗព្រោះមនុស្សនៅចំពោះមុខនាយជាអ្នកមានលុយកាក់ច្រើនគេចង់យ៉ាងណាគឺយ៉ាងនោះហើយ។ គិតដល់រឿងសំខាន់វិញទើបនាយនិយាយទៅកាន់គាត់មួយៗ៖

-លោកបង! ភីណាស្អែកចេញទៅផ្ទះហើយ! ខ្ញុំចង់ឲ្យនាងទៅនៅផ្ទះខ្ញុំមួយរយៈសិន!

បុរសជាបងរភ្នែកសម្លឹងមុខម្ចាស់សំណូមពរដែលហាក់ហួសហេតុពិបាកឲ្យគ្រួសារអភិជនមួយទទួលយកបាន។ វិទូត្រៀមលក្ខណៈរួចរាល់ក្នុងការតស៊ូពន្យល់គាត់បន្ទាប់ពីឃ្លាសំណូមពរនេះ។ គេនៅសម្លឹងមុខគាត់យ៉ាងទទូចហាក់រង់ចាំចម្លើយ។ ដឹងអីគាត់ស្រាប់តែងក់ក្បាលផ្ងក់ៗហើយនិយាយ៖

-ល្អដែរ! ផ្ទះមានរឿងច្រើនពេកហើយ! ឲ្យអូនទៅនៅថៃគេនៅទីនោះចុះ!

វិទូអរភើតដែលសុខៗគាត់ទទួលយកសំណូមពរខ្លួនងាយដល់ម្លឹង។ អ្នកពោលវិញ៖

-មីងម៉ាប់លែងនៅហើយ! មីងអូនទៅជាមួយភីណាទៀត បានអ្នកណានៅបម្រើលោកបង?

លោកកុសលច្បូតចិញ្ចើមដ៏ជ្រីវជ្រួញមុនអាយុរបស់គាត់ជាសញ្ញាបង្ហាញនូវបន្ទុកការងារដ៏ធ្ងន់ និងហេតុការណ៍អាក្រក់ហួសដែលធ្វើឲ្យគាត់ពិបាកនឹងសប្បាយចិត្ត។ បុរសមានប្រាក់ក្រាស់ក្រែលនិយាយមួយៗ៖

-កុំខ្វល់ពីខាងណោះ! បងផ្ញើភីណាផង! គឺផ្ញើយកតែមែនទែន! គឺបងទុកចិត្ត! ចំណែកខាងបងមានអ្នកបងនៅហើយ! តួនាទីគេជាប្រពន្ធគឺត្រូវថែទាំបម្រើប្ដី! ការងារប៉ុណ្ណឹងមិនចាំបាច់មានអ្នកជួយក៏បាន!

និយាយពីភរិយាគាត់ បុរសនៅតែបង្ហាញសេចក្ដីស្នេហាពេញក្រសែភ្នែក ម៉្លោះវិទូគិតច្រើនដងណាស់មុនពេលនិយាយទៅកាន់គាត់៖

-លោកបង! បើលោកបងទុកចិត្តខ្ញុំដល់ថ្នាក់ប្រគល់ភីណាមកឲ្យខ្ញុំថែទាំ ខ្ញុំក៏អត់មានអីត្រូវលាក់បាំងលោកបងដែរ! ខ្ញុំសង្ស័យថា នៅផ្ទះលោកបងមានអ្នកណាម្នាក់ចង់ធ្វើបាបភីណា!

លោកុសលងាកមករកអនាគតប្អូនថ្លៃដោយក្រសែភ្នែកមុត។ ពន្លឺភ្នែកគាត់ហាក់ចង់ប្រមូលយកអស់នូវអ្វីដែលកំពុងតែគិត ប៉ុន្តែគាត់មិនហើបមាត់ពោល ឬជំទាស់ជាមួយសម្ដីបង្ហើបដ៏គួរឲ្យភ្ញាក់ផ្អើលរបស់នាយឡើយ។

វិទូនិយាយបន្តដោយម៉ឺងម៉ាត់៖

-ការវិភាគបង្ហាញថាភីណាមិនមែនប្រើគ្រឿងញៀនជាប្រចាំមកទេពោលគឺក្នុងរវាងពេលចុងក្រោយនេះមានគេបន្លំសារធាតុរវើរវាយទៅក្នុងប្រអប់ថ្នាំនាង! ចំណែកនៅ Apartmentបឹងកេងកងនាងរន្ធត់ចង់លោតពីលើរានហាលក៏ដោយសារនាងមានសារធាតុសំយោគគ្រឿងញៀនច្រើនប្រភេទនៅក្នុងម្ហូបរបស់នាងដែរ! អ្នកធ្វើការទាំងពីរនេះតាមមើលជាមនុស្សតែមួយ!

លោកកុសលចាប់ញ័រមាត់ គាត់និយាយតតាក់តតុប៖

-ហេតុអីគេធ្វើបានប្អូនខ្ញុំ? អ្នកណា? វាជាអ្នកណា? ឯងត្រូវចាប់វាដាក់គុកវិទូ! ប្អូនឯងត្រូវជួយបងចំពោះរឿងនេះ! អត់បានទេ តោះយើងត្រឡប់ទៅមន្ទីរពេទ្យសិន! ភីណានៅតែពីរនាក់អ្នកអូនទេ!តោះយើង!

វិទូប្លែកចិត្តនិងស្មារតីទន់ខ្សោយរបស់គាត់។ យ៉ាងហោចណាស់អ្នកចាប់អារម្មណ៍ដឹងថាបុរសនេះស្រលាញ់ប្អូនលើសពីជីវិតរបស់គាត់។ អ្នកកំលោះពោលឃាត់៖

-ក្រែងម្សិលមិញខ្ញុំបានជម្រាបល្បួងថាខ្ញុំដាក់មនុស្សឃាមភីណា២៤ម៉ោងហើយនោះអី! សូមនៅទីនេះបន្តិចទៀតសិន ព្រោះខ្ញុំមានរឿងសម្ងាត់ខ្លះចង់ជម្រាប!

លោកកុសលងាកឆ្វេងស្តាំហាក់ប្រុងប្រយ័ត្នរួចទើបស្តីតប៖

-និយាយទៅវិទូ!

វិទូនិយាយមួយៗដោយផ្តោតភ្នែកលើទឹកមុខបុរសអ្នកមាន៖

-បងសល!ខ្ញុំសង្ស័យថាអ្នកបងជាអ្នករៀបចំសាច់រឿងទាំងអស់ធ្វើបាបភីណា!

ពន្លឺភ្នែកបុរសអភិជនទៅជាប្រែប្រួល គាត់ងាកមុខចេញមុនពេលសម្តីប្រែជាសោះកក្រោះ៖

-ប្អូនឯងស្មានផ្តេសផ្តាសស្អីហ្នឹង?

វិទូមិនថមថយតវិយាបថដោយរឹតតែពោលសង្កត់ពាក្យដាច់ណាត់៖

-ខ្ញុំសង្ស័យថា សម្តីភីណាជាការពិត ឯអ្នកបងជាមនុស្សកុហក!

លោកកុសលទំនងកាន់ជើងភរិយា គាត់ងាកមុខចេញលែងមើលមុខនាយប៉ូលិសយើងហើយនិយាយតបទាំងបែរខ្នង៖

-កោតណាស់!...ឬក៏ទូឯងជឿពាក្យភីណាដែលថាប្រពន្ធខ្ញុំស្លាប់កាលពីយប់នោះដែរ?

វិទូមិនបោះបង់ចោលការព្យាយាម គេប្រើក្រសែភ្នែកមុតថ្លាសម្លឹងបុរសដែលប្រឹងគេចវេះពីការពិត៖

-អ្នកបងអាចថាបានធ្លាក់ពីជណ្តើរនោះមែន តែគាត់បែរជាមិនស្លាប់គឺជារឿងពីរផ្សេងគ្នា! អាចថាក្រោយពេលភីណាចាកចេញពីផ្ទះគាត់បានដឹងខ្លួនឡើងវិញ តែប្អូនស្រីលោកមិនបានដឹងព្រោះនាងចូលមន្ទីរពេទ្យបាត់ហើយ!

លោកកុសលប្រកែកភ្លាម៖

-អត់ទេ! រឿងធ្លាក់ពីជណ្តើរអីអត់មានទេ គឺកុលាបមិនដឹងសោះ! គ្មានទាំងអស់!

វិទូនិយាយវិញប្រាវ៖

-បញ្ហាគឺនៅត្រង់នេះហើយ! ប្រសិនបើពេលភីណាចេញទៅបាត់គាត់ដឹងខ្លួនវិញក៏ដោយមានរឿងអីគាត់ចាំបាច់លាក់គ្រប់គ្នាពីហេតុការណ៍កាលពីយប់នោះ? ព្រោះតែគាត់ចង់ឆ្លៀតឱកាសនោះធ្វើឲ្យគ្រប់គ្នាយល់ថាភីណាមានបញ្ហាខួរក្បាលដោយសារគ្រោះថ្នាក់ចរាចរណ៍! បញ្ហាសំខាន់គឺគាត់បានយកថ្នាំវង្វេងវង្វាន់ទៅបន្លំក្នុងប្រអប់ថ្នាំនាង ដើម្បីឲ្យនាងនិយាយស្ដីកាន់តែផ្ដេសផ្ដាសឡើងដោយសារនាងខ្លាចផងភ័យផង ពេលគាត់ចូលទៅរក នាងគាត់ឆ្លៀតបញ្ចេញសកម្មភាពប្លែកៗឲ្យនាងយល់ថា គាត់ជាខ្មោចហើយទីបំផុតគឺនាងមិនអាចនៅផ្ទះនោះបាន!

លោកកុសលនៅតែឈរខាងភរិយាស្រស់ក្មេងរបស់គាត់  ដោយប្រកែកវិញញ័រមាត់៖

-វិទូ! ភីណាអាចថាឃើញខ្មោចមែន ព្រោះផ្ទះនោះគឺមានខ្មោចស្លាប់តែហោងគេកប់ចោលក្នុងផើងផ្កា ឯងក៏ឃើញ! ចំណែកថ្នាំរវើរវាយនោះ អាចថាអ្នកណាផ្សេងចង់ធ្វើបាបភីណាយើងក៏មិនដឹងដែរ!ចំណែកកុលាប គេមិនធ្វើអញ្ចឹងដើម្បីប្រយោជន៍អីទេ!

វិទូញញឹមជូរចត់៖

-តែសាកសពក្នុងផើងផ្កានោះ ជារឿងប្រឌិតទេ! កំណកដីជាប់នៅនឹងឆ្អឹងសពមានជាតិសំណខ្ពស់ខុសពីដីនៅកន្លែងផ្សេងក្នុងផើងនោះ វាបញ្ជាក់ថា ឆ្អឹងសពត្រូវបានដឹកមកពីទីផ្សេងដាក់បន្លំនៅក្នុងនោះដើម្បីឲ្យគូដណ្ដឹងខ្ញុំលែងព្រមចូលផ្ទះជាស្ថាពរ! ខ្ញុំមិនព្រមឲ្យភីណាត្រឡប់ទៅផ្ទះ ជាផែនការបណ្ដោះអាសន្នទេព្រោះខ្ញុំក្រែងពីសុវត្ថិភាពនាង ចំណែកថាឲ្យនាងចេញពីផ្ទះមួយជីវិតគឺទៅមិនរួចដាច់ខាតព្រោះនោះជាផ្ទះនាង គ្មានអ្នកណាម្នាក់អាចសម្រេចឧបាយកលទុច្ចរិតកម្ចាត់នាងចេញទេ!

លោកកុសលនិយាយលឺបលះ៖

-មើលទៅអ្វីដែលឯងនិយាយសុទ្ធតែរឿងស្មានៗទាំងអស់ទូ! បងមិនស្ដាប់ហើយមិនខ្វល់ទេ!

វិទូបន្តភ្លាម៖

-ទោះអញ្ចឹងក៏បងគួរទុកឱកាសមួយឲ្យខ្ញុំបញ្ជាក់សិនដែរថាខ្ញុំស្មាននោះត្រូវឬខុស!

លោកកុសលនៅស្ងៀម គាត់ឈ្ងោកមុខរិះគិតដោយតឹងតែងមិនចេញស្ដីធ្វើឲ្យវិទូបានឱកាសនិយាយបន្ថែមភ្លាមៈ

-លោកបង! ដើម្បីយុត្តិធម៌សម្រាប់ភីណា លោកបងឲ្យខ្ញុំបើកការស៊ើបអង្កេតទៅ!

លោកុសលនិយាយមួយៗៈ

-វិទូ! ភីណាគឺជាប្អូនស្រីតែមួយគត់របស់បង...តែក្នុងផ្ទះមានរឿងច្រើនរួចមកហើយ! បង.....គឺ...

-អញ្ចឹងហើយបានជាយើងត្រូវរកមធ្យោបាយបញ្ចប់រឿង! រឿងហេតុទាំងអស់កើតឡើងខុសទំនងទាំងស្រុងមានន័យថាមុខតែមានអ្នកណានៅពីក្រោយហើយ! បើបងគេចវេះបញ្ហា តើរឿងវាអាចចប់បានដោយរបៀបណាទៅ!

លោកកុសលនៅស្ងៀមបន្តិចទើបងក់ក្បាលសម្រេចចិត្តៈ

-បាន! កុំឲ្យថាបងមិនគិតពីភីណា! ឯងចង់ស៊ើបយ៉ាងម៉េច? តាមចិត្តព្រោះសនៅតែសខ្មៅនៅតែខ្មៅទេ! ប្រពន្ធបងអត់ខុស បងមិនខ្លាចអីទាំងអស់!

វិទូញញឹមស្មើៈ

-អញ្ចឹងបងត្រូវសន្យានឹងខ្ញុំថា ក្ដីនេះមិនឲ្យអ្នកបងដឹងសូម្បីតែតម្រុយបន្តិចឡើយ ទុកថាបងធ្វើដើម្បីប្អូនស្រីរបស់បងទៅចុះ!

លោកកុសលឆ្លើយផ្ទួងៈ

-បងក៏ចង់ជម្រះមន្ទិលឯងឲ្យអស់ដែរវិទូ។ បងគ្មានរឿងអីត្រូវទៅប្រាប់កុលាបរឿងអស់នេះទេ! ឯងធ្វើអីធ្វើចុះ! ព្រោះថ្ងៃមុខថ្ងៃក្រោយយើងជាគ្រួសារតែមួយ មានអ្នកដឹងរឿងថ្ងៃនេះច្រើននាំតែកើតរឿងមើលមុខគ្នាមិនចំទេ! បងនឹងលាក់ពីអ្វីដែលឯងទើបតែនិយាយនេះជារៀងរហូត!

វិទូបង្ហាញភាពជឿជាក់លើផ្ទៃមុខៈ

-ល្អណាស់! អញ្ចឹងយើងចាប់ផ្ដើមបានហើយ ជំហានដំបូងខ្ញុំសុំបងជួយឲ្យខ្ញុំបានឆែកឆេរបន្ទប់អ្នកបង!ភាគទី២០

តាមរយៈការរៀបចំរបស់លោកកុសល អ្នកទាំងពីរអាចចូលទៅត្រួតពិនិត្យក្នុងបន្ទប់គេងរបស់មេគ្រួសារនៃវីឡាស៊ីមស្តែនោះនៅថ្ងៃបន្ទាប់ គឺក្នុងពេលដែលអ្នកស្រីកុលាបដែលជាប់សង្ស័យត្រូវបានលោកកុសលប្រើឲ្យទៅដាក់ប្រាក់នៅធនាគារ។

វិទូនិងលោកកុសលឡើងទៅបន្ទប់នោះគេចបានពីការសង្ស័យរបស់ពូសួសដោយសារពួកគេជាញាតិអាចឡើងទៅពិភាក្សាកិច្ចការនានាដោយធម្មតាបាន។ ឈានចូលដល់បន្ទប់ដំណេកដែលបំពាក់ដោយសង្ហារិមមានតម្លៃពិបាកពណ៌នា វិទូរវៃភ្នែកសម្លឹងគ្រប់ទិសទីក្នុងពេលដែលលោកកុសលដើរទៅឈរដកដង្ហើមវែងនៅរានហាលខាងមុខបន្ទប់ដោយក្តីកង្វល់។

គាត់ងាកសម្លឹងបរិវេណខាងក្រោមនៃគេហដ្ឋានធំសម្បើមដែលចំណាយប្រាក់ជាច្រើនក្នុងការទិញមកសង្ឃឹមថាអាចផ្តល់ភាពកក់ក្តៅដល់ប្អូនស្រី និងភរិយា ប៉ុន្តែពេលនេះមានរឿងកើតឡើងជាបន្តបន្ទាប់រហូតដល់ល្ងាចនេះភីណាចេញពីពេទ្យហើយចាំបាច់ត្រូវទៅរស់នៅឯផ្ទះគូដណ្តឹងទៅវិញ។

-លោកបង!

សំឡេងហៅមិនខ្លាំង មិនស្រាលរបស់នាយប៉ូលិសដាស់អារម្មណ៍បាចហាចរបស់អភិជនរូបនេះឲ្យវិលមករាងកាយវិញ។ លោកកុសលដើរមួយៗត្រឡប់ចូលមកក្នុងបន្ទប់គេងខ្លួនដោយភ្នែកផ្តោតជាប់លើអ្វីម្យ៉ាងក្នុងដៃ។

កែវភ្នែកមុតថ្លារបស់គេដែលសម្លឹងមកកាន់គាត់បានធ្វើឲ្យគាត់ភ្ញាក់ផ្អើលជាស្រេចទៅហើយកុំថាឡើយដល់សំណួរបន្ថែមរបស់នាយ៖

-បងស្គាល់ថ្នាំនេះដែរ?

លោកកុសលចងចិញ្ចើមអង្គុយចុះយឺតៗសម្លឹងកូនដបក្នុងដៃអនាគតប្អូនថ្លៃដែលគេកំពុងកៀបនឹងដង្កៀបដែក។ ដៃគេមានពាក់ស្រោមតែដៃគាត់អត់ទេ គាត់លូកដៃទៅបម្រុងទទួលយកមកមើលតែត្រូវវិទូរាំង។ បុរសវ័យកណ្តាលងឿងឆ្ងល់ ឯនាយប៉ូលិសពន្យល់យឺតៗ៖

-បង! នេះគឺពពួកសារធាតុ3Mឈ្មោះពេញគឺ Magic Matrixyl Metal! មិត្តភ័ក្តិខ្ញុំបានផ្ញើឲ្យខ្ញុំនូវព័ត៌មានជាច្រើនទាក់ទងនឹងវានេះ! វាអាចជួយឲ្យផ្កាដែលដកចេញដើម្បីដាក់បន្លំកប់

សាកសពចូលនៅតែអាចរស់ស្រស់បស់ ហើយសារធាតុនេះ ពួកយើងរកឃើញនៅក្នុងផើងផ្កាសាកសពនោះដែរ!

លោកកុសលថ្លោះទឹកមុខ ហើយទ្រេតទ្រោតអង្គុយប៉ុកទៅលើគ្រែពូក។ ប្រតិកម្មរបស់គាត់បង្ហាញស្រេចហើយថាគាត់យល់ពីអ្វីដែលវិទូកំពុងនិយាយ។ នាយប៉ូលិសរូបនេះកៀបកូនដបទម្លាក់ទៅក្នុងស្បោងប្លាស្ទិកដោយមាត់ពោលបន្ត៖

-ប៉ុន្តែមិនដឹងប្រពន្ធបងដឹងឬអត់ថាទុករបស់នេះក្នុងបន្ទប់ដេកគ្រោះថ្នាក់កម្រិតណា ព្រោះថាប្រសិនបើច្រឡំប៉ះពាល់ដោយផ្ទាល់ជាតិពុលរបស់វា នឹងបង្កជាផលវិបាកធ្ងន់ធ្ងរបានជួនកាលប៉ះពាល់ដល់ជីវិតផង។

លោកកុសលនៅស្ងៀមដោយទឹកមុខខ្មៅរោលលែងនិយាយស្តីអ្វីបណ្តោយអោយវិទូលើកសម្ភារៈប្រើប្រាស់មួយចំនួនដែលមានសល់កម្ទេចដីដោយអន្លើបោសទម្លាក់ទៅក្នុងថង់មួយផ្សេងទៀតដោយកាយវិការយកចិត្តទុកដាក់។

ទោះបីវិទូមិនចាំបាច់និយាយ ក៏លោកកុសលដឹងដែរថាប្រាកដជាគេសង្ស័យដីនោះជាដីប្រភេទដែលគេបានវិភាគឃើញមានក្នុងជាប់ជាមួយសាកសពមានន័យថាអ្នកស្រីកុលាបជាភរិយាស្រស់ស្អាតរបស់ខ្លួនបានពាក់ព័ន្ធនឹងការជញ្ជូនឆ្អឹងខ្លែងក្លាយមកកាន់ទីនេះទើបសំលៀកបំពាក់ និងស្បែកជើងគាត់មានបន្សល់ដានស្នាមដីដោយអន្លើ។

វិទូធ្វើការខ្លួនដោយយកចិត្តទុកដាក់ទៅតាមជំនាញរបស់គេក្រោមទឹកមុខអស់សង្ឃឹមរបស់បុរសអភិជន។ ពេលចប់ការងារហើយ គេក៏ក្រោកឈររៀបចំចាកចេញដោយមិនភ្លេចងាកទៅរកម្ចាស់បន្ទប់ដែលកំពុងរុំព័ទ្ធទៅដោយភាពស្មុគស្មាញចាក់ស្រេះ៖

-លោកបង! ពេលការវិភាគចេញមក យើងនឹងដឹងថាដីទាំងនេះ និងថ្នាំក្នុងដបនេះជាប់ពាក់ព័ន្ធនឹងផើងផ្កានោះមែនដែរអត់ហើយ! ខ្ញុំបានដំណឹងភ្លាមនឹងជម្រាបបងមុនគេ!

លោកកុសលងើបមកយឺតៗហើយនិយាយតិចៗពីក្រោយខ្នងអនាគតប្អូនថ្លៃ៖

-វិទូ! អាចមានអ្នកណាម្នាក់ចង់ទម្លាក់កំហុសឲ្យកុលាបទេ?

វិទូសើចល្មួងចិត្តបុរសវ័យកណ្តាលដែលមិនមានកូនមួយគ្រាប់បន្តពូជពង្សនឹងគេ ហើយមកប៉ះរឿងភរិយាជាប់សង្ស័យទៀត។ នាយនិយាយតបវិញ៖

-បើទោះបីជារបស់ទាំងនេះជារបស់អ្នកបងមែន ហើយបើទោះការវិភាគចេញមកបង្ហាញថាគាត់មានទាក់ទងនឹងការទម្លាក់សពចូលក្នុងផងបញ្ឆោតឲ្យភីណាខ្លាចលែងហ៊ានចូលផ្ទះវិញមែន ក៏ប៉ុន្តែ ទោសនេះមិនធ្ងន់ណាស់ណាដែរ!

លោកកុសលស្ទើចបែបជូរចត់៖

-ហោចណាស់វាបង្ហាញពីភាពអពមង្គលក្នុងគ្រួសារខ្ញុំ! វាបញ្ចេញពីបរាជ័យរបស់ខ្ញុំក្នុងការធ្វើឲ្យស្រីម្នាក់ស្រលាញ់ប្អូនខ្ញុំឲ្យដូចដែលគេធ្លាប់សន្យា! វាក៏ជាអវសានវាទនៃស្នេហារបស់ខ្ញុំនិងនាងផងដែរ!

យល់ចិត្តគាត់ វិទូឈ្ងោកមុខនិយាយលួងពន្យល់គាត់វិញ៖

-លោកបង! រឿងគ្រួសារនៅតែជារឿងគ្រួសារ! បងមិនបាច់គិតពីមុខមាត់ពេកទេ! ជួនកាលផ្តើមចេញពីកំហុសលើកនេះលោកបងអត់ទោសឲ្យគាត់បាន អ្នកបងអាចនឹងភ្ញាក់ខ្លួនឡើងវិញផង! តែប្រសិនបើគាត់នៅតែចិញ្ចឹមចិត្តមិនចង់ឲ្យភីណានៅផ្ទះជុំជាមួយទៀត ចាំរកមធ្យោបាយបន្ត! រឿងបងប្អូនថ្លៃស្រីមិនត្រូវគ្នាកើតមានហូរហែរវាអត់មានអីចម្លែកទេ!

នឹកឃើញដល់រឿងផ្សេងលោកកុសលសួរវិញ៖

-ចុះរឿងធ្លាក់ជណ្តើរកាលពីយប់មានភ្លៀងធ្លាក់នោះ ឯងរកឃើញវិធីបញ្ជាក់ឬនៅទូ?

-ឃើញវត្ថុអស់នេះហើយ ចុះលោកបងជឿភីណាឬជឿប្រពន្ធបងឥឡូវនេះ?

លោកកុសលឆ្លើយតបវិញ៖

-វិទូ! ទោះបីរបស់អស់នេះបញ្ជាក់ថាកុលាបមានរឿងមួយចំនួនលាក់បាំងបង! ប៉ុន្តែមិនអាចបញ្ជាក់ការពិតនៅយប់នោះបានទេ! ឥឡូវនេះបងក៏ចង់ឲ្យឯងរកឃើញការពិតឲ្យបានឆាប់ៗដែរ! បងចង់ដឹងរវាងអ្នកទាំងពីរអ្នកណាជាអ្នកនិយាយពន្លើស!

-អញ្ចឹងហើយខ្ញុំត្រូវស្ទួរចម្លើយមនុស្សមួយចំនួន!

លោកកុសលបើកភ្នែកធំៗ៖

-មួយចំនួន? អ្នកណាខ្លះ? តែកុលាបនិងភីណាតទល់គ្នាដូចជាគ្រប់គ្រាន់ហើយដឹង?

វិទូគ្រវីក្បាល៖

-សេណារីយោនេះដូចជាមិនងាយស្រួលដល់ម្ល៉ឹងទេ! ខ្ញុំត្រូវការសួរមនុស្សពាក់ព័ន្ធមួយចំនួនទៀត!

-អ្នកណាខ្លះទៅ? (លោកកុសលសួរទាន់ហាន់)

-អ្នកបម្រើទាំងបីឥឡូវស្លាប់អស់ម្នាក់នៅពីរនាក់! និងក្មេងជំទង់ប្រុសស្រីពីរនាក់នៅជាប់ផ្ទះនេះផង!

លោកកុសលចងចិញ្ចើមសួរវិញ៖

-ក្មេងណា? មានទាក់ទងអីនឹងពួកគេ?

វិទូញញឹមដើរមកប្រឈមនឹងគាត់ហើយឆ្លើយតបវិញ៖

-ក្មេងប្រុសដែលកាលពីពេលយើងឃើញចោរចូលមកជីកផើងផ្ការកខ្សែកពេជ្រ គឺគេបានប្ដឹងប៉ូលិសទាន់ពេល! បងជឿថា រឿងហេតុជួនគ្នាម្ល៉ឹងដែរ?

លោកកុសលរវៃភ្នែករិះគិត៖

-ទូឯងចង់និយាយថា.....?

វិទូមមីភ្នែករបៀបត្រិះរិះតែមាត់ក៏មិនចោលប្រយោគសន្ទនា៖

-ក្មេងនោះតាមពិតមានបងស្រីគេម្នាក់ទៀតធ្លាប់រួចចូលមកក្នុងផ្ទះនេះនិយាយរឿងខ្មោចផ្ដេសផ្ដាសបន្លាចភីណា! ប៉ុន្មានថ្ងៃមុនកើតរឿងខ្ញុំធ្លាប់ជួបពួកគេ ស្មានថាក្មេងៗរាប់អានគ្នាធម្មតាប៉ុន្តែមួយរយៈក្រោយមកនេះបានខ្ញុំដឹងថាប្រធានបទដែលគេយកមកនិយាយនឹងភីណាអត់មានអ្វីក្រៅពីរឿងខ្មោចនោះទេ! ខ្ញុំសង្ស័យថាពួកគេជាគ្នារបស់អ្នកបង! ពួកគេរួមគ្នាបង្កើតរឿងខ្មោចឲ្យភីណាខ្លាចហើយលបទៅដាក់ថ្នាំក្នុងប្រអប់ថ្នាំរបស់នាងឲ្យអារម្មណ៍នាងរវើរវាយ បន្ទាប់មកក៏តាក់តែងឆាកខ្មោចលងជាបន្តបន្ទាប់ពង្វក់អារម្មណ៍នាង! ចុងក្រោយដើម្បីឲ្យអ្វីៗកាន់តែក្លាយជាការពិត គេបាននាំគ្នាដាក់ឆ្អឹងខ្មោចទៅក្នុងផើងនេះហើយយប់នោះធ្វើជានាំមនុស្សពីរនាក់នោះមកគាស់យកខ្សែកដោយមានម្នាក់នៅខាងក្រៅរង់ចាំប្ដឹងប៉ូលិស!

លោកកុសលនិយាយកាត់ផ្ទង៖

-ចោរពីរនាក់នោះសារភាពប្រាប់ប្អូនឯងអញ្ចឹង?

វិទូញញឹមចុងមាត់ នាយងក់ក្បាលផ្ងក់ៗមិនចេញស្តី។ លោកកុសលខាំមាត់ហើយពោលរអ៊ូៗ ៖

-ស្រីចង្រៃនោះ ចង់បានស្អីធ្វើរឿងច្រើនម្លឹងៗ?

វិទូបន្តពីប្រយោគប្រកបដោយកំហឹងរបស់បុរសម្ចាស់ផ្ទះ៖

-ស្រីៗ ជួនកាលស្អីក៏ហ៊ានធ្វើដែរ! ពិសេសដើម្បីមនុស្សដែលគេស្រលាញ់!

លោកកុសលបញ្ចេញភ្លើងកំហឹងតាមពន្លឺភ្នែក៖

-បើគេស្រលាញ់យើង ប្អូនយើងតែម្នាក់ប៉ុណ្ណឹងគេស្រលាញ់មិនបានមកធ្វើបាបនាងដល់ថ្នាក់ចូលពេទ្យម្តងជាពីរដង?

វិទូនិយាយលលេងមុនពេលចាកចេញទៅ៖

-លោកបងស្រលាញ់ប្អូនដល់ថ្នាក់ភ្លេចប្រពន្ធទេដឹង? ស្រីៗប្រចៃប្រចណ្ឌផុតលេខហើយអារឿងអញ្ចឹងៗ!

លោកកុសលនៅស្ងៀមក្រោមស្នូរជើង ចាកចេញរបស់នាយប៉ូលិស។

..ល្ងាចបន្ទាប់...

វិទូចូលទៅរកក្រមុំ ភីណាដ៏ស្រស់ប្រិមប្រិយដែលទើបតែចេញពីមន្ទីរពេទ្យថ្មីៗមកសម្រាកផ្ទះខ្លួនដោយមានអ្នកអួននៅតាមបម្រើព្រឹកល្ងាច។ អ្នកដើរមកដល់សួនច្បារក៏ឃើញនាងកំពុងមើលទស្សនាវដ្តីម្នាក់ឯងក្បែរកែវទឹកក្រូច។

គេនិយាយលេងជាមួយនាងបំបាត់ភាពអផ្សុកដែលស្រីស្អាតក្មេងវ័យត្រូវសាត់ឆ្ងាយពីផ្ទះមកនៅទីនេះដោយសាររឿងរ៉ាវជាច្រើនក្នុងរង្វង់គ្រួសារនាង។ ហើយចុងក្រោយគេ ក៏ភីណាស្ទាបស្ទង់ពីទំនាក់ទំនងនាងនិងបងថ្លៃស្រី។

-និយាយអញ្ចឹងមុនពេលមានរឿងរអិលពីលើជណ្ដើរនោះ អូនឯងនិងអ្នកបងធ្លាប់មានអីរអាក់អន់ចិត្តគ្នាទេ?

នារីរកនឹកបន្តិច ទើបតបមកកាន់អ្នកកំលោះ៖

-អត់ទេ! គឺធម្មតា!

-ចុះម៉េចក៏មួយរយៈក្រោយនេះដូចជា...??

ភីណាប្រញាប់បន្លឺទៅកាន់កំលោះគូស្នេហ៍៖

-មកពីគាត់និយាយកុហកអ្នករាល់គ្នាបានជាខ្ញុំស្អប់គាត់ទៅ!

-ចុះអូននៅតែជឿថាគាត់ស្លាប់បាត់ហើយដែរ?

សម្លឹងទៅសៀវភៅបរទេសមួយក្បាលដែលនៅលើដៃនាងក្រមុំកំពុងលើកបង្ហាញមកនោះ វិទូដើរចូលទៅអង្គុយក្បែរនាងទាំងលូកដៃទទួលយកសៀវភៅមកមើល សំឡេងភីណានៅតែពោលប្រាប់មកកាន់អ្នកកំលោះ៖

-ឯកសារអស់នេះបញ្ជាក់ថា ជួនកាលមនុស្សខ្លះអស់ដង្ហើមមួយខណៈដោយសារតែភ័យពេកបានន័យថាយប់នោះគាត់អាចគាំងដង្ហើមតែមិនស្លាប់ទេ! ប៉ុន្តែ ខ្ញុំឆ្ងល់តែរឿងដែលគាត់និយាយកុហកថាអត់មានរឿងអីកើតឡើងហ្នឹងឯង! ខ្ញុំមិនដឹងគាត់ចង់យ៉ាងម៉េចទេ! ចោរចូលផ្ទះមិនមែនកំហុសគាត់ទេ ហេតុអ្វីគាត់ចាំបាច់និយាយបំផ្លើសថាខ្ញុំឈ្លោះនឹងគាត់ហើយបើកឡានចេញ? ស៊ីយណាស់ ឡានបងសលនៅសុខៗដាច់ហ្វ្រាំងទៀត បើកុំអញ្ចឹង ខ្ញុំមិនមែនមានគ្រោះថ្នាក់ចូលពេទ្យច្រើនថ្ងៃទុកពេលឲ្យអ្នកបងបានភរគេឯងទេ!

វិទូដកភ្នែកពីសៀវភៅទៅដោយពោលសួរមកកាន់នាងក្រមុំយ៉ាងរហ័ស៖

-ឡានដាច់ហ្វ្រាំង?

ភីណាងក់ក្បាលផ្ងក់ៗដោយភ្នែកមូលក្លំងឿងឆ្ងល់នឹងប្រតិកម្មរបស់គូស្នេហ៍។ នាងមិនទាន់និយាយយ៉ាងណាទៀតផង ស្រាប់តែលឺវិទូសួររន្ថើនក្នុងសំឡេងខ្សឹបៗ៖

-ភីណា! រឿងឡានដាច់ហ្វ្រាំងមានអ្នកណាដឹងខ្លះ?

នារីឆ្លើយតបដោយងីងើនឹងប្រតិកម្មប្លែករបស់វិទូ៖

-អត់ឯណា! ខ្ញុំប្រាប់តែបងសលម្នាក់ហ្នឹង!

វិទូឈ្ងោកសម្លឹងដីរួចរិះគិតមិនចេញស្ដីធ្វើឲ្យស្រីស្អាតទៅជាញញឹម។ នាងបត់សៀវភៅទុករួចនិយាយ៖

-បងឯងកុំស្មុគពេក! ឥឡូវខ្ញុំឈប់គិតរឿងអស់ហ្នឹងហើយ!

វិទូមិនឆ្លើយតបថាយ៉ាងណាផង ក៏ស្រាប់តែលីភីណានិយាយបន្ថែម៖

-ខ្ញុំទើបនឹងដឹងថា កន្លងមកធ្វើឲ្យបងសលពិបាកចិត្តច្រើនណាស់! ម្ខាងប្រពន្ធម្ខាងប្អូន! ខ្ញុំគិតទៅមិនសមរវើរវាយធ្វើរឿងផ្ដេសផ្ដាសម្ល៉ឹងៗទេ!

ភីណានិយាយចប់ភ្លាម វិទូបន្លឺសួរភ្លាមដែរ៖

-ភីណា! លោកបងស្រលាញ់អូនណាស់មែនអត់?

ភីណាបូញមាត់ឆ្លើយភ្លាម៖

-ត្រូវហើយ! គាត់ត្រូវតែស្រលាញ់ខ្ញុំអញ្ចឹង! បងឯងហ៊ានធ្វើបាបខ្ញុំ គង់តែដឹងទេ!

វិទូដៀងភ្នែកសម្លឹងមកនាង អ្នកកំលោះបន្លឺសួរមួយៗបន្ថែម៖

-ចុះលោកបងស្រលាញ់អ្នកបងដែរទេ?

នាងបន្លឺតបវិញភ្លាម៖

-បងសលជួបអ្នកបងកាលគាត់ទៅបារាំងរកស៊ី! អ្នកបងនៅទីនោះរៀនពេទ្យបានតែពីរឆ្នាំក៏សុខចិត្តមករៀបការជាមួយលោកបង! ពួកគាត់ស្រលាញ់គ្នាណាស់! គាត់ចាស់ជាងអ្នកបងជាង១០ឆ្នាំ អ្នកបងស្អាតហើយក្មេងទៀតរឿងអីថាគាត់មិនស្រលាញ់!?

វិទូងើបមុខសម្លឹងនាងក្រមុំដែលកំពុងរៀបរាប់ប្រាប់អ្នកកំលោះៗសញ្ជឹងគិតស្ងាត់ៗក្នុងចិត្តតែម្នាក់ឯង៖

“តើតាមពិតទៅស្ត្រីនោះត្រូវការអ្វីឲ្យប្រាកដ? ហើយរវាងប្ដីប្រពន្ធនោះមានរឿងអ្វី?”

-អូ៎បងគិតទៅដល់ណាហើយហ្នឹង?(នាងពញ្ញាក់អ្នកកំលោះ)

វិទូឆ្លើយតបៈ

-បងកំពុងគិតថា សូម្បីតែអូនឯងក៏អាយុតិចជាងបងសល់ច្រើនហួសដែរ!

ភីណាលាន់មាត់ដោយទឹកមុខខិចខ្ចក់ៈ

-អញ្ចឹងបានបងប្រុសគេស្រលាញ់គេដឹងអត់? បងឯងច្រណែន??

ភ្លាមនោះទំនងដូចជានឹកឃើញដល់រឿងអ្វីមួយវិទូងាកមករកសួរនាងបន្ថែមៈ

-ភីណាអ្ហ៎ា?

-ចាំ!

-ចុះបើថ្ងៃណាមួយ ប៉ូលិសរកឃើញថាអ្នកបងធ្វើរឿងខុសត្រូវជាប់ទោសដល់ថ្នាក់ជាប់គុកជាប់អី អូនគិតយ៉ាងម៉េច?

ភីណាធ្លាក់ទឹកមុខ នាងគិតបន្តិចទើបដាច់ចិត្តឆ្លើយៈ

-ក្នុងចិត្តខ្ញុំ អ្នកបងបានស្លាប់តាំងពីយប់នោះមកម្ល៉េះ! ឥឡូវនេះស្រីដែលនៅផ្ទះខ្ញុំមិនដឹងជាអ្នកណាផងទេ!ហើយបើគេធ្វើអ្វីខុសច្បាប់ អ្នកណាធ្វើអ្នកហ្នឹងទទួល ខ្ញុំមានអីទៅខ្វល់កើត!

-ចុះបើគាត់ជាបងស្រីបង្កើតរបស់អូនវិញហើយត្រូវជាប់ទោសអូនគិតម៉េចវិញភីណា?

ស្រីស្អាតបញ្ចេញភាពទាក់ទើរលើផ្ទៃមុខរហូតដល់ក្លាយជាសញ្ញាតឹងតែងអារម្មណ៍ហាក់ខ្វិលគិតនាងក៏គ្រវីក្បាលនិយាយភ្លាមៈ

-មិនដឹងទេ! នៅសុខៗមកសួរសំណួរអពមង្គល! ខ្ញុំមានបងស្រីពីណាមកបើមានរឿងអីគាត់ទៅធ្វើអាក្រក់នោះ?

វិទូដឹងថានាងទើបតែចេញពីពេទ្យមិនចង់ធ្វើឲ្យនាងគិតច្រើនប្រុងនិយាយសម្រួលអារម្មណ៍ស្រីមកវិញស្រាប់តែលឺសូរទូរសព្ទរោទ៍។គេងាកនិយាយជាមួយនាងក្រមុំមុនពេលចាកចេញទៅនិយាយទូរសព្ទៈ

-ភីណា! តិចទៀតញុាំបាយជាមួយគ្នា!

នាងក្រមុំញញឹមដោយគ្មានមន្ទិលសង្ស័យ។ អ្នកកំលោះដើរចាកចេញពីនាងទុកឲ្យស្រីតូចបន្តការអានរបស់នាង។ ឯអ្នកកំលោះវិញចុចទទួលទូរសព្ទដែលកំពុងលាន់ឡើងញាប់រន្ថាន់ដោយពោលសួរបន្ត៖

-ម៉េចហើយ?

សំឡេងពីចុងម្ខាងឆ្លើយតបវិញដោយប្រញាប់ប្រញាល់៖

-រកឃើញអស់ហើយ! ចាំជួបគ្នាចាំនិយាយ!

វិទូរត់តម្រង់ម៉ូតូវាក់អើរនឹងអ្នកអួនកំពុងលើកអាហារសម្រន់តម្រង់សួនច្បារបម្រើអ្នកនាងតូចរបស់គាត់ កំលោះនាយប៉ូលិសនិយាយទៅកាន់គាត់ភ្លាម៖

-មីង! ប្រាប់អ្នកនាងមីងផង ខ្ញុំមានការងារបន្ទាន់នៅកន្លែងធ្វើការ កុំឲ្យគេចាំបាយខ្ញុំ!

ក្រោមផ្ទៃមេឃហៀបអស្តង្គតសាជាថ្មី វិទូមកដល់ភូមិគ្រឹះធំស្កឹមស្កៃរបស់លោកកុសល។ អ្នកកំលោះឈានជើងចូលក្នុងផុតព្រំរបងតាមការស្វាគមន៍របស់ពូសួសទន្ទឹមនឹងពេលប៉ូលិសផ្នែកព្រហ្មទណ្ឌមួយឡានទៀតមកដល់ដែរ។

-ពូ! ពួកខ្ញុំសុំអញ្ជើញអ្នកបងទៅប៉ុស្តិ៍ដើម្បីសាកសួររឿងរ៉ាវខ្លះ!

បុរសអ្នកថែសួនប្តូរទឹកមុខព្រោះថាទោះបីយ៉ាងណាការដែលប៉ូលិសនាំគ្នាមកច្រើនហើយសួររកអ្នកស្រីរបស់ខ្លួន គ្មានសញ្ញាថាពួកគេនាំមកនូវរឿងរ៉ាវល្អនោះទេ។ គាត់ឱនកាយគោរពក្រុមសមត្ថកិច្ចជាមួយវាចាសមរម្យ៖

-ខ្ញុំឡើងទៅជម្រាបអ្នកស្រីភ្លាម!

បុរសអ្នកថែសួនដើរចូលទៅក្នុងផ្ទះធំដោយមានវិទូឈានចូលតាមពីក្រោយឃើត។ បន្ទាប់មកប៉ូលិសពីរបីនាក់ឈានចូលទៅជាមួយដែរ។

គេមិនឆ្ងល់ទេចំពោះភាពស្ងាត់ជ្រងំនៃគេហដ្ឋាននេះ ព្រោះតាំងពីភីណាចាកចេញ មីងម៉ាប់ស្លាប់ មីងអួនទៅតាមបម្រើអ្នកនាងតូចគាត់ក្នុងផ្ទះសល់តែលោកកុសលភរិយាគាត់និងបុរសថែសួននេះប៉ុណ្ណោះ។

ពួកប៉ូលិសឈរជាក្រុមពីរនាក់ និងបីនាក់ជជែកគ្នារអ៊ុះៗដោយសម្លឹងបរិវេណផ្ទះទាំងយកចិត្តទុកដាក់ បណ្ដោយឲ្យពេលវេលាមួយនាទីអូសបន្លាយទៅរហូតដល់បីនាទី.....។ វិទូងើបមុខសម្លឹងទៅជាន់ខាងលើ អ្នកកំលោះឃើញពូសួសរត់ត្រហេបត្រហបមកដោយទឹកមុខស្លេកស្លាំង.....ដោយសង្ស័យអ្នកកំលោះស្ទុះរឹងទៅកាន់ទីនោះតាមជណ្ដើរថ្មើរជើងជាមួយសំណួរក្នុងពេលទន្ទឹមគ្នា៖

-ឯណាអ្នកបង?

តាមពិតដែលពូសួសចំណាយពេលយូរព្រោះអ្នកស្រីសំងំក្នុងបន្ទប់មិនព្រមបើកទ្វារតាមការគោះហៅរបស់គាត់សោះ ម្ល៉ោះហើយក្រុមប៉ូលិសបានសម្រេចចិត្តទម្លាយទ្វារចូលទៅខាងក្នុង។

អ្នកស្រីកុលាបដែលពួកគេចង់ជួបកំពុងស្ថិតនៅក្នុងស្ថានភាពដង្ហើមចង្រិតហើយរាងកាយគាត់ពោរពេញដោយដំបៅស្នាមរលួយដូចជាប្រតិកម្មហ្នឹងអ្វីមួយ។ ស្ត្រីនោះនៅមានដង្ហើមនៅឡើយ គាត់ខំបើកភ្នែកប្រឹមៗពេលឃើញវិទូ  ហើយគាត់ត្រដាបត្រដួសចង់ក្រោកពីលើគ្រែមករកនាយ។

វិទូតក់ស្លុត អ្នកនិយាយតិចៗតែដាច់ណាត់ទៅកាន់ប៉ូលិសក្រោមបង្គាប់៖

-ហៅឡានពេទ្យ!

គេលូកយកម៉ាសមកពាក់ហើយនិងស្រោមដៃដោយស្ទុះចូលទៅក្បែរស្ត្រីរងគ្រោះ។

-អ្នកបង! តាំងស្មារតីឡើង!

បបូរមាត់ស្ត្រីនោះកម្រើកហាក់ចង់និយាយអ្វីមួយតែអណ្ដាតគាត់រឹងនិយាយមិនចេញបានត្រឹមបញ្ចេញសំឡេងអឺះៗនិងទឹកភ្នែកហូររហាម។        វិទូងៀងភ្នែកទៅរកពូសួសដែលឈរញ័រខ្លួនចំប្រប់នៅខាងក្រោយខ្នង អ្នកពោលសួរម៉ាត់ៗ៖

-ពូសួស! ឯណាលោកបង?

បុរសបានបម្រើឆ្លើយដោយទឹកភ្នែកអាណិតម្ចាស់ស្រី៖

-ទានប្រុសទៅថៃកាលពីព្រឹកមិញ! គាត់ចោលការងារនៅទីនោះយូរក្រែលដែរដោយសារអ្នកនាងតូចភីណាឈីបានអ្នកនាងចេញពីពេទ្យភ្លាមគាត់ឆ្លៀតទៅភ្លាម! គាត់ថាស្អែករសៀលត្រឡប់មកវិញហើយ!

វគ្គទី១១

វត្ថុតាងចុងក្រោយ

....លោកកុសលចូលមកកាន់ច្រកទ្វារប្រលានយន្តហោះដោយទឹកមុខរលះរលាំង។ វិទូនិងប៉ូលិសពីរបីនាក់ទៀតនៅទីនោះស្រាប់ដើរតម្រង់មករកគាត់ហើយពួកគេបាននាំបុរសអភិជនឡើងរថយន្តដែលបញ្ចេះចាំជាស្រេច។

ឡានបោលចេញសឹងមិនទាន់ បុរសអភិជនហើបមាត់សួរភ្លាម៖

-ប្រពន្ធខ្ញុំកើតអី?

កំលោះអនាគតប្អូនថ្លៃនៅស្ងៀម តែគូកនគេម្នាក់ងើបមុខតបមករកលោកកុសលដោយម៉ឺងម៉ាត់៖

-ខ្ញុំជាពេទ្យកោសល្យវិច័យ! ខ្ញុំឆ្លើយនឹងសំណួរលោកចុះ! អ្នកស្រីកុលាបមានស្ថានភាពចេញដំបៅរលួយពេញទាំងខ្លួន ថ្លើមនិងសរីរាង្គខាងក្នុងផ្សេងទៀតមានជាតិពុលជ្រៀតចូល៨០ភាគរយ!ស្ថានភាពគាត់មិនខុសពីស្ត្រីបម្រើលោកដែលឈ្មោះម៉ាប់នោះទេ! គឺបានប៉ះពាល់ផ្ទាល់ជាមួយសារធាតុគីមីអ្វីម្យ៉ាងដ៏សាហាវ!

លោកកុសលប្តូរទឹកមុខ គាត់ងាកសម្លឹងទៅតាមដងផ្លូវដែលរថយន្តកំពុងបោលកាត់ គាត់និយាយស្រងូត៖

-ខ្ញុំចង់ជួបនាង!

ប៉ូលិសម្នាក់ផ្សេងទៀតនិយាយកាត់ផួង៖

-សុំទោស! ពួកខ្ញុំត្រូវនាំលោកទៅសាកសួរនៅប៉ុស្តិ៍!

ភាគ២១

លោកកុសលបើកភ្នែកមូលក្លុំដោយភ្ញាក់ផ្អើល គាត់ងាកមើលមុខមនុស្សគ្រប់គ្នាដោយពន្លឺភ្នែកមុត បន្ទាប់មកបញ្ឈប់ភ្នែកនៅត្រង់អនាគតប្អូនថ្លៃ៖

-វិទូ! ហេតុអ្វីត្រូវសួរចម្លើយបង? ប្រពន្ធបង ប្អូនបង គ្រោះថ្នាក់បន្តបន្ទាប់ ឥឡូវមិនឲ្យបងទៅពេទ្យមើលប្រពន្ធ នាំបងទៅប៉ុស្ដិ៍ធ្វើអី បងទើបមកពីក្រៅ បងមិនដឹងហេតុការណ៍អីទាំងអស់ ឥឡូវនេះបងត្រូវការទៅមើលកុលាប!

វិទូងាកមុខចេញដោយទើសទាល់ ប៉ុន្ដែប៉ូលិសម្នាក់លូកមាត់កាត់ធ្វើហី៖

-ទៅឃើញនាំតែខកចិត្តទេ!

លោកកុសលងាកថ្ងៃទៅរកម្ចាស់ប្រយោគដោយសង្ស័យសួរ៖

-ចង់មានន័យថាម៉េច?

ប៉ូលិសនោះសើចចុងមាត់ងាកមុខចេញសម្លឹងទៅដងផ្លូវធ្វើមិនដឹង។ ទីបំផុតបុរសអ្នកជំនួញដ៏ល្បីឈ្មោះត្រូវបានបញ្ជូនមកកាន់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ក្រោមការមិនពេញចិត្តរបស់គាត់។នៅក្នុងបន្ទប់សួរចម្លើយដែលមានប៉ូលិសបីនាក់ដោយមានវិទូម្នាក់ក្នុងចំណោមនោះផងលោកកុសលចាប់ផ្ដើមប្រយោគជាមួយពាក្យគម្រាម៖

-មេធាវីខ្ញុំកំពុងមកហើយ! ខ្ញុំមិនត្រូវការឆ្លើយអីទាំងអស់!

ប៉ូលិសឈ្មោះភ័ណសើចញញឹមនិយាយបញ្ឈឺគាត់៖

-លោកនាយកក្រុមហ៊ុន! ឥឡូវនេះលោកមិនចង់ដឹងពីស្ថានភាពភរិយាលោកទេ?

ភ្លាមនោះលោកកុសលបន្លឺឡើងភ្លាម៖

-ខ្ញុំចង់ដឹងហ្នឹងហើយបានជាខ្ញុំទាមទារទៅមើលនាង!

ប៉ូលិសដដែលសើចហើយឆ្លើយ៖

-ខ្ញុំប្រាប់ហើយថាលោកទៅនាំតែខកចិត្ត!

លោកកុសលសម្លក់ប៉ូលិសនោះភ្លែដោយក្រសែភ្នែកកាចសាហាវ ជាពន្លឺភ្នែកដែលធ្វើឲ្យវិទូក៏ភ្ញាក់ផ្អើលព្រោះគាត់បង្ហាញចរិតប្លែកស្រឡះមិនដែលឃើញពីមុនមក។ គាត់មិនសួរតែប៉ូលិសនោះងមើលបន្តៈ

-ព្រោះថា អ្នកស្រីកុលាបមិនទាន់ស្លាប់ដូចដែលលោកចង់បានទេ!

លោកកុសលដៀងភ្នែកសន្សឹមៗសម្លឹងមុខមនុស្សទាំងបីនៅពីមុខខ្លួន។ គាត់មិនចេញស្តីមួយម៉ាត់ប៉ុន្តែពន្លឺភ្នែកគាត់ដូចជាមានសំណួរជាស្រេចទៅកាន់ពួកគេថា «ពួកឯងដឹងអស់ហើយ?»

ពេលវេលាអូសបន្លាយទៅដោយស្ងៀមស្ងាត់ វិទូដែលស្ងាត់ស្ងៀមពីវាលយន្តហោះរហូតមកដល់ទីនេះចាប់ផ្តើមនូវប្រយោគដំបូងរបស់ខ្លួនៈ

-ហេតុអីលោកបងធ្វើអញ្ចឹង? សម្លាប់មនុស្សគឺខុសច្បាប់បងដឹងទេ! ពេលភីណាដឹង នាងទទួលយកបានដែរ?

លោកកុសលធ្វើមុខស្មើហើយងាកមុខគេចចេញៈ

-ឯងនិយាយឆ្កួតយោអីវិទូ?

វិទូមិនឆ្លើយ តែប៉ូលិសភ័ណបោះឯកសារមួយសំណុំទៅលើតុហើយបើកចេញបង្ហាញនូវលុយដុល្លារអាមេរិកសន្លឹក១០០មួយសំណុំ។

-ស្អីគេ? (លោកកុសលដៀងភ្នែកមើលបន្តិចហើយសួរ)

-លុយប៉ុន្មានសន្លឹកនេះមានលេខរៀងបន្តបន្ទាប់គ្នាដោយសារវាមកពីសំណុំបាច់តែមួយ! ហើយខ្លះត្រូវបានលោកផ្ញើតាមវិទូឲ្យទៅគ្រួសារមីងម៉ាប់ពេលគាត់ស្លាប់ ខ្លះត្រូវបានរកឃើញលើខ្លួនជនសង្ស័យពីរនាក់ ហើយខ្លះទៀតត្រូវបានរកឃើញក្នុងហាងមាសយីហោគង់ពីរ។

លោកកុសលក្រឡាប់គ្រាប់ភ្នែកទំនងគាត់ស្មានមិនដល់ក្នុងពេលដែលវិទូនិយាយបន្តពីគូកនៈ

-លុយដែលលោកបងឲ្យខ្ញុំយកទៅឲ្យមីងម៉ាប់ ហើយនិងលុយទិញខ្សែកពេជ្រពីហាងគង់ពីរ និងលុយដែលចោរពីរនាក់ឡើងទៅកាប់ផើងផ្ការកខ្សែក ហេតុអ្វីក៏ចេញពីបាច់តែមួយ? វាមានតែម្យ៉ាងប៉ុណ្ណោះគឺបងឯងជាអ្នកទិញខ្សែកពេជ្រទៅទម្លាក់បន្លំក្នុងផើងផ្កា ហើយក៏ដាក់

សាកសពក្លែងក្លាយទៅក្នុងនោះដោយជួលអាពីរនាក់កាលពីយប់នោះឲ្យនិយាយបំភ័ន្តការពិតបង្កើតរឿងប្រឌិតសម្លាប់អ្នកបម្រើ។

លោកកុសលសើចខឹកៈ

-ឯងស៊ើបក្តីដល់ឆ្កួតហើយវិទូ? ខ្ញុំទៅធ្វើរឿងអញ្ចឹងធ្វើអី? ដើម្បីបំភ័យប្អូនខ្លួនឯង? ក្រែងឯងដឹងហើយអ្វីៗគឺស្រីនោះជាអ្នកធ្វើដើម្បីធ្វើបាបភីណាប្អូនខ្ញុំ ឥឡូវបាបកម្មតាមទាន់ឲ្យជាតិគីមី 3Mប៉ះមកលើស្បែកវាខ្លួនឯងដល់ថ្នាក់រលាករលួយពុលថ្លើមស្ងួតដូចឯងឃើញស្រាប់ម៉េចក៏មិនគិត?

វិទូសួរបញ្ច្រាសៈ

-សម្តីបងពេលនេះបង្ហាញថាទំនាក់ទំនងប្តីប្រពន្ធបងមិនល្អប្រសើរដូចដែលគេគ្រប់គ្នាបានគិតពីមុនមកទេ!

បុរសនោះនៅតែការពារខ្លួនៈ

-ក្រែងឯងជាអ្នកប្រាប់បងដោយផ្ទាល់ថាស្រីនោះធ្វើបាបភីណាអ្អេស? បងមិនងប់កន្ទុយក្បិនទេ បើស្រីនោះធ្វើបាបប្អូនស្រីបង! បងការពារម៉េចកើត?

វិទូមិនមាត់តែប៉ូលិសភ័ណសួរវិញភ្លាមៈ

-ចុះម៉េចលោកដឹងថា អ្នកស្រីរបួសព្រោះសារធាតុ3M? អូភ្លេចឲ្យឈឹង កាលពី១៨ឆ្នាំមុនលោកជានិស្សិតនៅសាកលវិទ្យាល័យ Université Pierre et Marie Curie លោកជានិស្សិតដ៏ពូកែផ្នែកអនុវត្តន៍ប៉ុន្តែបានបោះបង់ចោលការសិក្សាពាក់កណ្តាលទីព្រោះតែវិបត្តិក្នុងរង្វង់គ្រួសារ។ ពេលដែលឪពុកម្តាយលោកស្លាប់ទៅ លោកក្លាយជាភាគហ៊ុនធំនៃសហព័ន្ធពាណិជ្ជកម្មមួយចំនួន ហើយលោកក៏មានឈ្មោះល្បីក្នុងចំណោមពួកអ្នកមានប្រាក់រហូតដល់គ្មានអ្នកណាចាប់អារម្មណ៍ថាលោកក៏ជាអ្នកឯកទេសគីមីដ៏គ្រាន់បើម្នាក់ដែរនោះទេ។ នៅប្រលានយន្តហោះគ្រាន់ខ្ញុំនិយាយត្រួសៗពីស្ថានភាពប្រពន្ធលោក លោកអាចទាយដឹងថានាងត្រូវពុលដោយសារធាតុ3Mលោកពិតជាមិនបានបោះបង់ចោលជំនាញចាស់ទៅតាមពេលវេលាមែន!

លោកកុសលទះតុផាំងៈ

-ពួកឯងអាងអីមកស៊ើបប្រវត្តិខ្ញុំ!? អ្វះ? សក្តិឯងពាក់ធ្ងន់ពេកចង់របូតម្តង?

វិទូនិយាយមួយៗ៖

-បងកុសល! ពេលនេះយើងសង្ស័យថាបងបំពុលអ្នកបងកុលាប និងបានទម្លាក់សាកសព ក្លែងក្លាយទៅក្នុងផើងផ្កាព្រមទាំងបានបំពុលអ្នកបម្រើឈ្មោះម៉ាប់ទៀត! យកល្អបងសារភាពទៅ! ភស្តុតាងនិងសាក្សីយើងមានអស់ហើយ!

លោកកុសលសម្លក់វិទូខ្មែរ គាត់និយាយផ្លួនសួរ៖

-ភស្តុតាង? សាក្សី?

ប៉ូលិសម្នាក់ទៀតដើបតម្រង់ទៅមាត់ទ្វារទាញបើកដើរចេញក្រៅបន្សល់ទុកលោកកុសលនៅទីទើរម្នាក់ឯងកណ្តាលបន្ទប់ស្ងាត់ច្រៀបក្រោមពន្លឺភ្នែកតាមដានរបស់វិទូនិងភ័ណ។ ម្នាក់នោះត្រឡប់មកវិញជាមួយស្ត្រីរាងទាបកន្តាល់ធាត់កន្ទុតដែលរុំក្បាលដោយក្រមានិងមានទឹកមុខក្រៀមក្រំ។ លោកកុសលសម្លឹងស្ត្រីនោះដោយភាន់ភាំង គាត់ចំណាយពេលបន្តិចទើបចំណាំបានថាជាស្ត្រីបម្រើឈ្មោះម៉ាប់ដែលគាត់គិតថាបានស្លាប់ទៅហើយ។

-ឯង....ឯង....ម៉ាប់អ្វែស៎? ចុះក្រែងឯងស្លាប់ហើយមែនទេ?

មីងម៉ាប់ដែលជ្រុះសក់អស់ពីក្បាលលើកក្រមាចេញបង្ហាញលោកកុសលដែលរវើ្មរកកលគេចវេះមិនហ៊ានមើល។ ស្ត្រីនោះយំផងនិយាយផង៖

-នេះជាស្នាដៃរបស់ទានប្រុសដែលធ្វើមកលើខ្ញុំ! ខ្ញុំបម្រើគ្រួសារនេះជាយូរមកហើយ! ម៉េចក៏ទានប្រុសធ្វើអញ្ចឹងមកលើខ្ញុំ?

-មីងទៅវិញចុះ! (ប៉ូលិសភ័ណនិយាយក្នុងពេលលោកកុសលឱនសម្លឹងដីគោះជើងទាំងពីរធ្វើមិនដឹង)

ប៉ូលិសដដែលនាំមីងម៉ាប់ចាកចេញទៅបន្សល់នៅមនុស្សដដែលជាមួយនិងការសួរចម្លើយ។ វិទូចាប់ផ្តើម៖

-យើងបានរកឃើញថា បងមានពាក់ព័ន្ធជាមួយរឿងរ៉ាវរញ៉េរញ៉ៃតាំងពីពេលដែលភីណាត្រូវពុលជាតិថ្នាំរំញោចនៅApartmentបឹងកេងកង! ដំបូងយើងសង្ស័យថាអ្នកបងជាអ្នកធ្វើបាបភីណា....

លោកកុសលមិនរង់ចាំឲ្យវិទូបញ្ចប់ប្រយោគទាន់ទេគាត់ស្រែកកាត់ដោយកំហឹង៖

-បើមិនស្រីចង្រៃនោះតើអ្នកណា?

វិទូតាមពិតគឺទើបតែជឿក្នុងថ្ងៃនេះថាលោកកុសល គឺស្អប់ភរិយាវ័យក្មេងរបស់ខ្លួនជាខ្លាំងខុសពីសកម្មភាពរបស់គាត់ដែលធ្វើជាការពារភរិយាពីសម្តីមិនដឹងខ្យល់របស់ភីណាកាលនៅឯផ្ទះធំ។

វិទូនិយាយបន្តទៀត៖

-លោកបងជាអ្នកមានជំនាញផ្នែកគីមីស្រាប់លោកបងដឹងមុនគេថាភីណាគឺត្រូវថ្នាំរំញោចនៅពេលដែលនាងត្រឡប់ពីមន្ទីរពេទ្យចូលមកនៅក្នុងផ្ទះ។ ថ្ងៃនោះលោកបងរត់ទៅរកនាងនៅApartmentបឹងកេងកងព្រោះដឹងថាអ្នកបងមិនចោលគំនិតព្យាបាទនាងទេហើយលោកបងក៏ទៅទាន់ចំពេលនាងទើបនឹងហូបសាច់គោចៀនរួចដែលអ្នកបងចំអិនផ្ញើតាមអ្នកម៉ាប់ទៅ! សារធាតុរំញោចនោះមានលក្ខណៈខ្ពស់ហួសហេតុរហូតដល់ភីណាប្រុងលោតសម្លាប់ខ្លួនពីជាន់លើធ្វើឲ្យលោកបងឈឺចាប់នឹងគុំគួនទុក។ សន្តិសុខនៅក្រោមនោះនិយាយថាលោកបងបានសំណូមពរឆែកវីដេអូហើយទីបំផុតលោកបងបានរកឃើញថាប្រពន្ធខ្លួនជាអ្នកយកសាច់នេះមកឲ្យមីងម៉ាប់នៅជាន់ផ្ទាល់ដី។ ចាប់ពីពេលនោះមកលោកបងបានរៀបចំគម្រោងការកម្ចាត់ភរិយាខ្លួនឯងដើម្បីសេចក្តីសុខភីណា។ លោកបងបានរកសាកសពមកដាក់បន្លំក្នុងផើងជាមួយខ្សែកពេជ្រដែលមានត្រាយីហោពីហាងគង់ពីរហើយជួលមនុស្សពីរនាក់នោះឲ្យដើរតួល្ខោនជាមួយប៉ូលិសដោយចុងក្រោយឲ្យពួកគេឆ្លើយបន្លំថា អ្នកស្រីជាអ្នកនៅពីក្រោយរឿងអស់នេះ។ ចុងក្រោយពេលអ្នកបងត្រូវពួកខ្ញុំសង្ស័យ លោកបងក៏ឡើងទៅបំពុលអ្នកបងមុនពេលចេញទៅប្រទេសថៃដោយសង្ឃឹមថាពេលអ្នកបងស្លាប់គ្រប់គ្នានឹងគិតថាដោយសារគាត់ពាក់ព័ន្ធនឹងរឿងយកសាកសពដាក់ក្នុងផើងទើបត្រូវជាតិ3Mដល់ស្លាប់ខ្លួនឯង។ ចុងក្រោយគ្មានអ្នកណាសង្ស័យបងទាំងអស់ព្រោះមានមនុស្សតិចណាស់ដែលដឹងថាបងធ្លាប់

មានប្រវត្តិជានិស្សិតគីមីវិទ្យានៅប្រទេសបារាំង ហើយសារធាតុ3M នេះគឺបងមានវិធីកែច្នៃវាមកប្រើបាន!

លោកកុសលសើចដោយជូរចត់ គាត់និយាយបន្ទរៈ

-ពួកឯងពូកែណាស់ហ្ន៎!

បន្ទាប់មកគាត់ដំឡើងសំឡេងគំហកៈ

-បើពូកែអញ្ចឹងម៉េចឯងមិនចេះការពារគូដណ្ដឹងឯងកុំឲ្យស្រីមានពិសនោះធ្វើបាបទៅ ម៉េចក៏បណ្ដោយភីណាចូលពេទ្យម្ដងហើយម្ដងទៀត!

វិទូនិយាយតបមួយៗហាក់មិនខ្វល់នឹងកំហឹងអនាគតបងថ្លៃៈ

-អ្នកបងអាចទុកឲ្យច្បាប់កាត់ទោសគាត់! យើងគ្មានសិទ្ធិធ្វើអីគាត់ទេ! យើងត្រូវការភស្តុតាង!

លោកកុសលស្រែកដោយកំហឹងៈ

-យូរណាស់! ទម្រាំពួកឯងធ្វើការចេញប្អូនខ្ញុំស្លាប់បាត់ហើយក៏មិនដឹង! ឯងដឹងទេថ្នាំរំញោចចុងក្រោយដែលវាដាក់ឲ្យភីណានៅ Apartment បឹងកេងកងតើជាថ្នាំអីទេ? contamination ecstasyកម្រិត៣! រវាង៥នាទីវាធ្វើឲ្យគាំងបេះដូងស្លាប់ភ្លាមបាន! ស្រីបិសាចនោះបំណងវាមិនមែនឲ្យភីណាចេញពីផ្ទះទេគឺសម្លាប់ភីណាចោលតែម្ដង! បើខ្ញុំមិនទៅដល់ទីនោះទាន់សង្ឃឹមពួកប៉ូលិសអស់ឯងប្អូនខ្ញុំស្លាប់តែហោងក្នុងដៃស្រីនោះបាត់ហើយ!

ប៉ូលិសភ័ណក្រពាត់ដៃដើរជុំវិញតុ គេនិយាយមួយៗដោយសំឡឹងជនសង្ស័យនៅចំពោះមុខៈ

-អញ្ចឹងហើយបានជាថ្ងៃនោះ មីងម៉ាប់ឃើញលោកដាក់ថ្នាំមួយគ្រាប់ទៅក្នុងមាត់ភីណាភ្លាមទើបនាងទន់ខ្លួនលែងកញ្ជ្រោល! ដោយសារគ្រាប់ថ្នាំនោះនិងសម្ដីមីងម៉ាប់ដែលសួរថា តើនោះជាថ្នាំអ្វីធ្វើឲ្យលោកដាច់ចិត្តប្រើជាតិ3Mសម្លាប់គាត់បំបិទដាន?

លោកកុសលបញ្ចេញទឹកមុខសាហាវ។ គាត់ទ្រេតខ្លួនខែងរ៉ែងទៅលើកៅអីហើយនិយាយតប៖

-សារភាពក៏បាន! ឯងថាស្រីពីរនាក់នោះគ្មានអ្នកណាស្លាប់ អញ្ចឹងទោសយើងក៏មិនធ្ងន់ដែរ! មានអីខ្លាច! យើងធ្វើមែនប៉ុន្តែយើងធ្វើដើម្បីការពារខ្លួន! ពួកឯងស្តាប់ឲ្យច្បាស់ ហើយធ្វើរបាយការណ៍ឲ្យត្រឹមត្រូវទៅ!

ប៉ូលិសភ័ណធ្វើសញ្ញាឲ្យគ្នីគ្នាម្នាក់ទៀត។ ប៉ូលិសនោះចាប់ផ្តើមចុចថតសំឡេងនិងលើកប៊ិចមកត្រៀមកត់ត្រា។ ទឹកមុខលោកកុសលពោរពេញទៅដោយការឈឺចាប់ គាត់និយាយមួយៗដូចលង់ក្នុងក្តីសុបិនៈ

-តាមពិតមិនមែនខ្ញុំមិនទុកឱកាសឲ្យស្រីចង្រៃនោះកែខ្លួនទេ ប៉ុន្តែវាជាមនុស្សមិនចោលពុត! ម្តងជាពីរដង វានៅតែចង់សម្លាប់ភីណា បើខ្ញុំមិនចាត់ការវាឲ្យបានទាន់ពេល មានតែនៅរង់ចាំមើលប្អូនស្រីខ្ញុំត្រូវគេសម្លាប់។...នៅថ្ងៃដំបូងដែលភីណាចូលមន្ទីរពេទ្យ ខ្ញុំភ័យណាស់ព្រោះមិនដឹងនាងកើតអីខ្លះហើយបន្ទោសខ្លួនឯងដែលទៅរកស៊ីចោលផ្ទះសម្បែងចោលប្រពន្ធនិងប្អូនស្រី។ ពេលប្រពន្ធខ្ញុំកុហកថាភីណាចចេសឈ្លោះជាមួយគេហើយបើកឡានចេញពីផ្ទះទាំងកណ្តាលយប់ ខ្ញុំគ្រាន់តែនឹកឆ្ងល់ថាហេតុអ្វីមានរឿងខឹងគ្នាដល់ម្ល៉ឹង ប៉ុន្តែមិនសង្ស័យអីទេព្រោះប្រញាប់ទៅមើលប្អូននៅពេទ្យ។ដឹងអីពេលនាងដឹងខ្លួនឡើងកាលណាឱបខ្ញុំយំហើយនិយាយថាឡាននោះដាច់ហ្វ្រាំង។ ខ្ញុំនឹកចម្លែកចិត្តនឹងរឿងនេះ ហើយពេលមកដល់ផ្ទះភីណាចេញសកម្មភាពប្លែកៗដាក់កុលាបធ្វើឲ្យខ្ញុំចេះតែសង្ស័យខ្លាំងឡើងរហូតដល់តាមដានដឹងថាគេត្រូវរ៉ូវគ្នាជាមួយក្មេងជក់គ្រឿងញៀនពីរនាក់នៅជិតផ្ទះដែលត្រូវការលុយទិញថ្នាំញៀនហើយរួមដៃគ្នាកុហកភីណាឲ្យខ្លាចខ្មោចឡើងវង្វេងវង្វាន់គួបផ្សំនឹងជាតិថ្នាំរវើរវាយដែលលួចប្តូរក្នុងប្រអប់ថ្នាំភីណាផង។

វិទូសួរកាត់ផ្ទួងៈ

-បងចង់និយាយពីបងប្អូនជំទង់របស់និស្សិតស្រីមកពីបរទេសហ្នឹង?

-វាមិនមែនមកពីបរទេសណាទេគឺជាមនុស្សដែលកុលាបជួលមកហើយឲ្យលួចចូលមកផ្ទះតាំងពីរាត្រីមានភ្លៀងធំដែលភីណាគ្រោះថ្នាក់ឡាននោះ គឺនាងឃើញពីរនាក់បងប្អូននោះនៅរានហាលបន្ទប់វត្ថុបុរាណដែលកុលាបជួលមក ពួកវាពាក់អាវភ្លៀងពណ៌ខ្មៅបំភ័យភីណាហើយបន្ទាប់មកកុលាបធ្វើជាដួលនិងអត់ដង្ហើមខ្លួនឯងដើម្បីឲ្យភីណាស្លន់ស្លោចេញពីផ្ទះ។ ខ្ញុំបានរកឃើញសំបកថ្នាំសណ្តំដែលស្រីមានពុតនោះប្រើដាក់សណ្តំពូសួស អ្នកអួននិងមីងម៉ា

ប់ដើម្បីធ្វើយ៉ាងណាឲ្យភីណាចេញទៅបើកឡានតែឯង ចំណែកហ្វ្រាំងឡាននោះគឺវាបានកាត់ផ្ដាច់រួចជាស្រេច។

ភាគ២២

វិទូនឹកភ្នកឡើងវិញដល់សម្ដីគូដណ្ដឹងដូចកាលពីនៅថ្មីៗ។ នាងនិយាយថាយប់នោះមិនត្រឹមតែដាស់ឈ្នួលបម្រើគ្មានអ្នកក្រោកទេសូម្បីតែទូរសព្ទក៏ដាច់អស់ដែរ។ នាយសួរបកទៅបុរសអភិជនវិញ៖

-ចុះដឹងរឿងពិតហើយម៉េចក៏បងមិនប្ដឹងប៉ូលិស?

លោកកុសលពេបមាត់៖

-ក្រែងឯងជាប៉ូលិសហើយតើ! យើងមិនឃើញថាបានការអីក្នុងការរកជំនួយពីប៉ូលិសទេបានជាយើងសុខចិត្តឡើងទៅដោះស្រាយជាមួយស្រីនោះផ្ទាល់មាត់!

ប៉ូលិសភ័ណចំហមាត់ធ្លុង តែប៉ូលិសដែលកត់របាយការណ៍សួររឹង៖

-អូ! មានន័យថាលោកបានទៅបកអាក្រាតអ្នកស្រីកុលាបរួចហើយ? តើគាត់ទទួលទេ? គាត់ដឹងខុសទេ?

លោកកុសលសើចខឹកហាក់ចំអកឲ្យខ្លួនឯង គាត់និយាយបន្ត៖

-មកពីខ្ញុំខ្វាក់ភ្នែកជឿសម្ដីលួងលោមរបស់វាបានជាកាលពីមុនសុខចិត្តលើកស្ទួយយកវារៀបការឡើងជាអ្នកស្រីមានលុយចាយហូរហៀរដែលតាមពិតវាគ្រាន់តែជានិស្សិតអាហារូបករណ៍ផ្នែកគីមី សាស្ត្រវក់ធ្វើការក្រៅម៉ោងលំបាកយ៉ាប់យ៉ឺននៅស្រុកបារាំង! ពេលបានផ្ទះធំទ្រនំខ្ពស់វាភ្លេចធាតុដើមកើតចិត្តច្រណែនសូម្បីតែប្អូនថ្លៃខ្លួនឯង! សូម្បីតាមទាន់ល្បិចកលស្មោកគ្រោករបស់វាហើយខ្ញុំមិនដាច់ចិត្តប្ដឹងប៉ូលិសទេគ្រាន់តែនិយាយព្រមានវា វាមិនត្រឹមមិនដឹងកំហុសថែមទាំងគឃ្លើនឈ្លោះនឹងខ្ញុំជានិច្ចកាលទៀតធ្វើឲ្យផ្ទះទាំងមូលដូចរស់កណ្ដាលភ្នក់ភ្លើង។

វិទូទ្រាំមិនបានចំពោះការនិយាយកាន់ជើងតែម្ខាងនេះក៏លូកមាត់៖

-តែអ្នកបងប្រាប់ថាលោកបងជួបមេធាវីផ្ទេរមរតក៩០%ទុកឲ្យភីណា! នេះជារឿងអយុត្តិធម៌សម្រាប់គាត់បំផុតដែលធ្វើឲ្យគាត់ឈឺចិត្តទ្រាំមិនបាន!

លោកកុសលខាំមាត់សង្រ្កឹតធ្មេញ៖

-ស្រីអត់មារយាទនោះជិតស្លាប់ហើយឆ្លៀតនិយាយរឿងអស់នេះប្រាប់ប៉ូលិសបានទៀត?

ប៉ូលិសភ័ណលូកមាត់កាត់ម្តង៖

-ចម្លែកដែរដែលលោកឯងខុសគេ ចែកលុយឲ្យប្អូនច្រើនជាងប្រពន្ធដល់ម្លឹងរឿងអីគេមិនច្រណែនកើតជារឿងរ៉ាវចងអាឃាតគ្នា?

លោកកុសលនៅស្ងៀមមិនឆ្លើយតែវិទូនិយាយស្រាលៗតែច្បាស់ៗទៅកាន់គាត់ទាំងសម្លឹងមុខគាត់យ៉ាងមុត៖

-ព្រោះប្រពន្ធចុងមិនអាចទុកស្មើកូនស្រីទេ!

ប៉ូលិសភ័ណបើកភ្នែកធំៗក្នុងពេលលោកកុសលឆ្លួលចុងច្រមុះ។ សំឡេងវិទូបន្លឺមកបន្ថែមស្រាលៗ៖

-នៅឆ្នាំ១៩៩៥គឺនៅមុននេះ១៨ឆ្នាំ និស្សិតគីមីវិទ្យាម្នាក់បានចោលការសិក្សាកណ្តាលទីមកស្រុកកំណើតវិញដោយសារមានវិបត្តិក្នុងគ្រួសារគឺឪពុកខ្លួនបានរៀបការភរិយាវ័យស្មើប្អូនខ្លួន។ មិននឹកស្មានថា ទីបំផុតវិបត្តិលើកនោះបានធ្វើឲ្យនិស្សិតគីមីនោះជួបស្នេហាពិតជាមួយម្តាយចុងក្មេងរបស់ខ្លួន ហើយពួកគេបានលួចលាក់រួមរស់រហូតដល់បង្កើតបានទារិកាម្នាក់ដែលមនុស្សគ្រប់គ្នាក្នុងសង្គមជាន់ខ្ពស់ស្មានថានោះជាប្អូនស្រីរបស់គេ ហើយគេក៏បានលាក់កំបាំងឪពុកហៅនាងថាជាប្អូនរហូតមក ប៉ុន្តែនិស្សិតនោះបានស្រលាញ់ប្អូនស្រីស្មើជីវិតរបស់គេ ទោះបីក្រោយពីឪពុកនិងម្តាយចុងនោះមានគ្រោះថ្នាក់ចរាចរណ៍ដល់ជីវិត ក៏គេសុខចិត្តនៅព្រៅម្នាក់ឯងកណ្តោចកណ្តែងលើលោកនេះមិនព្រមរៀបការអ្នកណាជាប្រពន្ធឡើយរហូតដល់គេបានជួបជាមួយអ្នកស្រីកុលាប។គឺពេលនោះភីណាមានអាយុ១៤ឆ្នាំទៅហើយ។ ការបែងចែកមរតក៩០ភាគរយទៅឲ្យកូនស្រីដោយរំលងចោលប្រពន្ធបច្ចុប្បន្នជារឿងដែលធ្វើឲ្យភាគីខាងស្រីផ្ទុះកំហឹងនិងចងអាឃាត!

ភ្លាមៗនោះលោកកុសលស្រាប់តែស្ទុះរឹងពីកៅអីទៅទាញកអាវវិទូទាំងគ្រហឹមដោយកំហឹង៖

-ស្រីចង្រៃនោះជាអ្នកបើកកកាយអតីតកាលនេះប្រាប់ឯង? វាបានរស់នៅទំនេរស្រណុកនៅមិនសុខជួលគេឲ្យស៊ើបប្រវត្តិប្តី សមទេ? ហើយដែលឯងនិយាយចេញមកនេះឯងមានគិតដល់ភីណាអត់អា ចង្រៃ?!

ប៉ូលិសពីរនាក់ទៀតជួយទាញគាត់ចេញ វិទូគំហកវិញទាំងខឹង៖

-អញ្ចឹងបងឯងចេះគិតណាស់? បើបងឯងចេះគិតបងឯងបង្ករឿងឲ្យធំដូចពេលនេះធ្វើអី? បងឯងធ្វើរឿងឧក្រិដ្ឋប៉ះពាល់ដល់ជីវិតមនុស្សម្តងហើយម្តងទៀត រឿងអីថាគេមិនស៊ើប រឿងអីគេមិនដឹងពីឫសគល់អតីតកាលរបស់ភីណា? មុនធ្វើ បងឯងមានគិតអត់? បើអ្នកបងមានគំនិតមិនល្អបងឯងចេះចង បងក៏គួរចេះស្រាយទៅ ហេតុអ្វីទៅជាសម្លាប់គ្នាទៅវិញទៅមក?

ភាគ២២

ប៉ូលិសភ័ណរាំងដៃឃាត់ធ្វើឲ្យវិទូទប់កំហឹងថយទៅអង្គុយកន្លែងដើមវិញ តែលោកកុសលមិនបានបញ្ឈប់ទេគាត់និយាយបន្តរ៉ាវ៖

-មកពីស្រីពុតត្បុតនោះមិនព្រមបញ្ឈប់! នៅបឹងកេងកងពេលដែលវាប្រើជាតិ contamination ecstasyកម្រិត៣ដក់ក្នុងម្ហូបភីណា យើងបានសម្រេចចិត្តរួចហើយថា ដរាបណាវាមានជីវិត អ្នកដែលស្លាប់គឺភីណា! ពេលនោះយើងដាក់ថ្នាំបន្សាបជាតិញៀនទៅក្នុងមាត់ប្អូនស្រីយើង ស្រីអ្នកបម្រើមិនដឹងខ្យល់នោះបែរជាឃើញហើយនៅមិនស្ងៀមមកសួរនាំយើងថាដាក់អ្វីក្នុងមាត់នាង? ក្នុងពេលប្រថុចញ៉ុចដែលយើងផ្ទុះកំហឹងហើយគិតថាត្រូវសម្លាប់កុលាបចោល យើងក៏មិនចង់ឲ្យអ្នកណាម្នាក់ដឹងថាយើងបានបន្សាបថ្នាំភីណា ហើយដឹងថាយើងយល់អស់ពីឧបាយកលរបស់កុលាបទេ។ ដូច្នេះយើងបង្ខំចិត្តត្រូវតែបំបិទមាត់មីងម៉ាប់។

ប៉ូលិសកត់ត្រាងក់ក្បាលៗផ្ងក់ៗហាក់យល់ការណ៍៖

-លោកឯងចង់បាញ់ព្រួញមួយទទួលសត្វពីរ! មិនត្រឹមតែបំបិទមាត់គាត់ទេ ថែមទាំងធ្វើឲ្យយើងយល់ខុសថា  អ្នកស្រីកុលាបប្រើសារធាតុ3Mសម្លាប់គាត់!

ប៉ូលិសភ័ណនិយាយម្តង៖

-ប៉ុន្តែនៅព្រឹកនោះ នៅពេលលោកឯងលាបជាតិថ្នាំទៅលើថានក្បានដែលបញ្ជាឲ្យគាត់ប្រមូលលាងគាត់បានពុលជាបណ្តើរៗហើយសុំត្រឡប់ទៅសម្រាកផ្ទះ។ នៅពេលគាត់កាន់តែមិនស្រួលខ្លាំងក្រុមគ្រួសារបានបញ្ជូនទៅស្រុកកំណើតដែលនៅទីនោះគាត់មានសំណាងបានជួបគ្រូខ្មែរពូកែៗដែលមានមធ្យោបាយបន្សាបជាតិពុលនេះដោយថ្នាំបុរាណបាន! ពេលពួកយើងទៅដល់ គាត់បានអង្វរយើងឲ្យនាំដំណឹងមកលោកថាគាត់ឈឺធ្ងន់ឲ្យលោកជួយផងព្រោះគាត់ឃើញផ្ទាល់ភ្នែកថាពេលប្អូនស្រីលោកធ្វើទុក្ខលោកមានវិធីដាក់ថ្នាំតែមួយគ្រាប់ចូលមាត់នាងក៏លែងអី! ពេលនោះហើយដែលប៉ូលិសចាប់សង្ស័យថា ហេតុអ្វីលោកចេះវិធីព្យាបាលសារធាតុរំញោច? ហេតុអ្វីមីងម៉ាប់ដឹងរឿងនេះហើយបែរជាធ្លាក់ខ្លួនឈឺធ្ងន់? លោកស្គាល់ប្រភេទគ្រឿងញៀនក្នុងខ្លួនប្អូនស្រីលោកមានន័យថា លោកក៏ដឹងពីអ្នកដែលនៅពីក្រោយរឿងនេះដែរ!

វិទូនិយាយបន្តពីគូកនៈ

-ពេលជួបមីងម៉ាប់ហើយ ខ្ញុំបានមកប្រាប់បងវិញថាគាត់ស្លាប់ ប៉ុន្តែតាមពិតចាប់ពីពេលនោះមកបងបានធ្លាក់ក្នុងបញ្ជីអ្នកជាប់សង្ស័យទៅហើយ! ក្រោយមកការគិតរបស់យើងបានក្លាយជាការពិតគឺនៅពេលដែលលុយប៉ុន្មានសន្លឹកដែលបងផ្ញើតាមខ្ញុំទៅឲ្យគ្រួសារមីងម៉ាប់ លុយរកឃើញលើខ្លួនជនសង្ស័យពីរនាក់ និងលុយទិញខ្សែកពេជ្រនៅហាងមាសឃីហោគង់ពីរមានលេខរៀងបន្តបន្ទាប់គ្នាដោយសារនៅបាច់តែមួយ!

នៅស្មៀមបន្តិចទើបគេនិយាយបន្តៈ

-តែខ្ញុំនៅគិតមិនយល់រឿងមួយ! ថាហេតុអ្វីបានជាលោកបងដឹងថាក្មេងពីរនាក់នោះបានតែងរឿង កុហកភីណាអំពីករណីសម្លាប់អ្នកបម្រើរហូតដល់លោកបងបង្កើតល្ខោនកប់សាកសពក្នុងផើងនិងដាក់ខ្សែកពេជ្រទម្លាក់កំហុសលើអ្នកបង?

លោកកុសលសើចរលាក់ខ្លួន មួយសន្ទុះក្រោយមក គាត់ក៏និយាយបន្តៈ

-តាំងពីពេលដែលប្អូនស្រីយើងចូលពេទ្យជាលើកទីពីរគឺយើងបានដេញស្រីចង្រៃនោះត្រឡប់ទៅផ្ទះវិញទុកតែយើងម្នាក់តទល់ជាមួយភីណា! ពេលនាងដឹងខ្លួនលើកទីមួយយើងបានជជែកលួងលោមនាង ហើយបង្ហាញថាព្រមជឿនាងទាំងអស់ ដោយលើកទឹកចិត្តឲ្យនាងនិយាយហេតុការណ៍ពីដើមដល់ចប់ដែលនាងបានឆ្លងកាត់នោះឡើងវិញតាមលំដាប់លំដោ

យ។ ពេលនោះហើយដែលយើងដឹងថាសូម្បីតែក្មេងចម្លួតពីរនាក់នៅក្បែរផ្ទះនោះ ក៏មានចំណែកមកតំណាលប្រាប់រឿងបោកប្រាស់កុហកឲ្យភីណាជឿថាមានខ្មោចបិសាច។ គ្មានអ្វីពិសេសទេ! ក្រោយមកនេះគឺយើងគ្រាន់តែប្រើល្បិចទល់ល្បិចគឺយើងគ្រាន់តែធ្វើឲ្យរឿងកុហករបស់ពួកវាក្លាយជាការពិតឡើងប៉ុណ្ណោះ។ ពួកវាប៉ុន្មានអ្នកនោះក៏មិនស្មានដល់ដែរថាហេតុអ្វីក្នុងផើងនោះមានសាកសព។ នៅក្រោយពេលប៉ូលិសបញ្ជូនសាកសពក្លែងក្លាយចេញទៅគឺកុលាបសង្ស័យទៅហើយថាហេតុអ្វីបានជាទៅជាដូច្នេះ ព្រោះរឿងបម្រើត្រូវសម្លាប់ក្នុងផ្ទះបាយជារឿងដែលវាបង្គាប់ឲ្យក្មេងពីរនាក់នោះនិយាយកុហកភីណាចុះហេតុអ្វីចោរពីរនាក់នោះនិយាយដូចបានឃើញហេតុការណ៍ពិតរហូតដល់ថាមានខ្សែកធ្លាក់ក្នុងនោះទៀត? នៅយប់មានដែលវារមៀលធ្លាក់ចុះពីជណ្តើរគឺក្មេងចំកួតពីរនាក់នោះទទូរអាវភ្លៀងខ្មៅបន្លាចភីណា ចុះម៉េចក៏ចោរពីរនាក់ដែលឡើងកាប់ផើងផ្កាឆ្លើយថា ថ្ងៃនោះជាពួកគេដែរ?

ប៉ូលិសភ័ណនិយាយបន្ត៖

-អ្នកស្រីកុលាបហេតុតែសង្ស័យ បានទៅពិនិត្យផើងថ្មនោះសាជាថ្មី តែសំណាងមិនល្អព្រោះលោកបានលាបសារធាតុ3Mចាំទទួលគាត់។ បន្ទាប់មកលោកក៏ទម្លាក់សំបកដប3Mនៅកន្លែងសម្ងាត់មួយក្នុងបន្ទប់អ្នកស្រីកុលាបនិងសម្ភារៈគួរសង្ស័យមួយចំនួនទៀតធ្វើឲ្យវិទូឡើងទៅឆែកឆេរយល់ខុសថា អ្នកស្រីកុលាបជាអ្នកទម្លាក់សាកសពក្លែងក្លាយនោះជាមួយសារធាតុ3Mទីបំផុតក៏ពុលស្លាប់ខ្លួនឯង!នៅពេលស្បែកគាត់ចាប់ផ្តើមរលួយលោកក៏ចាកចេញទៅធ្វើជំនួញនៅបាងកកធ្វើមិនដឹងខ្លួនដោយសង្ឃឹមថាពេលវិលមកវិញកាលណាសត្រូវក្បែរទ្រូងនឹងស្លាប់ផុតពីលោកនេះទៅហើយ ដឹងអីវិទូឆ្លាតជាងលោកមួយជំហាន ថ្នាំបុរាណនៅភូមិចាស់របស់មីងម៉ាប់អាចជួយពន្យារស្ថានភាពរបស់អ្នកស្រីកុលាបធ្វើឲ្យគាត់អាចនិយាយរឿងជាច្រើនប្រាប់យើង!

ប៉ូលិសដែលកត់ត្រាបញ្ឈប់ប៊ិចដកដង្ហើមវែង ហើយងើបមុខនិយាយមួយៗ៖

-លោកកុសល ឥឡូវនេះលោកជាប់សង្ស័យពីករណីធ្វើឃាតដោយចេតនាពីរលើក មេខ្លោងបញ្ជាឲ្យមានការលួចសាកសពនិងភ្លុងក្នុងគេហដ្ឋានខ្លួនឯង បង្កើតនិងប្រើប្រាស់សារធាតុញៀនកម្រិតធ្ងន់ និងជាតិគីមីដែលត្រូវបានហាមឃាត់ដោយច្បាប់! យើងមានសាក្សីនិងវត្ថុតាងគ្រប់គ្រាន់ក្នុងការបញ្ជូនលោកឲ្យទៅការពារខ្លួននៅតុលាការ!

លោកកុសលសើចស្ងួតក្រោមពន្លឺភ្នែកក្រៀមក្រំរបស់អនាគតប្អូនថ្លៃ។ គាត់ត្រូវបានគេទាញឲ្យក្រោករុញឲ្យដើរចេញត្រង់ទ្វារ មុនពេលចេញទៅគាត់ងាកមករកវិទូជាមួយទឹកមុខត្រជាក់ស្រឹប៖

-ចាំឲ្យច្បាស់! បើឯងធ្វើបាបភីណា ធ្វើឲ្យនាងពិបាកចិត្ត យើងនឹងសម្លាប់ឯង!

បុរសដែលងប់ងុលស្រលាញ់កូនឥតខាន់ស្លាក្រោមស្លាកថាប្អូនស្រីបានចាកចេញទៅក្រោមអារម្មណ៍រន្ធត់របស់វិទូ។ មិនមែនអ្នកកំលោះភ័យព្រួយចំពោះប្រយោគគម្រាមចុងក្រោយនេះទេ ប៉ុន្តែគឺអ្នកកំលោះដឹងថាអ្នកកំលោះកំពុងប្រឈមមុខសាជាថ្មីជាមួយគូដណ្ដឹង។

-កំពុងគិតថាត្រូវនិយាយជាមួយគូដណ្ដឹងយ៉ាងម៉េចអ្ហេស៎? (ភ័ណទះស្មាវិទូតិចៗ)

វិទូនៅស្ងៀមប៉ុន្តែតាមពិតគឺគេកំពុងតែតឹងតែងចិត្តជាមួយបញ្ហាប្រឈមគ្រានេះមែន។ គេកំពុងគិតថា តើភីណានឹងទទួលអារម្មណ៍បែបណានៅពេលដឹងការពិតទាំងអស់នេះ?

សំឡេងគូកនដឹងចិត្តថ្លើមលាន់មកបន្ត៖

-សំខាន់គឺ ត្រូវធ្វើយ៉ាងណាឲ្យនាងយល់និងទទួលយកការពិតនេះឲ្យបាន ទោះបីឈឺចាប់រយៈពេលខ្លីតែមិនត្រូវលាក់កំបាំងនាងដូចដែលលោកកុសលលាក់បាំងជាមួយភរិយាគាត់ទេ! មនុស្សនៅជាមួយគ្នាត្រូវស្មោះត្រង់នឹងគ្នា!

វិទូបង្ហាញពីភាពស្មុគស្មាញក្នុងចិត្តដោយរអ៊ូតិចៗល្មមលឺតែពីរនាក់៖

-ភ្ជាប់ពាក្យជាមួយភីណាតាំងពីតូចព្រោះប៉ាខ្ញុំនិងប៉ានាងកាលនៅរស់ជាមិត្តជិតដិត! តែប៉ុន្មានឆ្នាំមកនេះគេលាក់បានជិតល្អណាស់! គ្មានអ្នកណាដឹងថាតាមពិតលោកបងនិងម្ដាយចុងគាត់មានស្នេហាលួចលាក់រហូតដល់បានភីណាទេ! ត្រង់នេះខ្ញុំក៏មិនបន្ទោសគាត់ដែរ រឿងនេះជាអតីតកាលនិង ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះកិត្តិយសផង មិនមែនចង់និយាយក៏និយាយចេញមកបាននោះទេ អ្នកនាងក៏មិនគួររវល់តែរឿងអតីតកាលនាំល្អក់កករដល់ចំណងអាពាហ៍ពិពាហ៍បច្ចុប្បន្នកាលដែរ!

ភ័ណកៀកស្មាគេដើរផងនិយាយផង៖

-តែបញ្ហារបស់គាត់គឺរឿងមរតកនោះ! ទីបំផុតគាត់បែកការណ៍ឲ្យអ្នកស្រីនោះដឹងពីរឿងចែកទ្រព្យមិនស្មើ បានជាប្រពន្ធកើតចិត្តសង្ស័យទៅតាមដានរុករកទាល់តែឃើញមូលហេតុពិត! ទោះមានកូនស្រីមុនក៏ដោយប្រពន្ធក៏ត្រូវតែស្រលាញ់ទើបគ្រួសារបានសុខនឹងគ្នា កំហុសត្រង់នោះគឺគិតកូនចោលប្រពន្ធ!...តែណ្ហើយ...ទោះយ៉ាងណាយើងអ្នកក្រៅដឹងមិនច្បាស់ដូចសាមីខ្លួនពួកគេទេ! ចាំស្តាប់ម្ខាងទៀតប្រាប់សិនបានដឹងថារឿងពិតវាយ៉ាងណា!

ប្រាវ....ព្រះភិរុណបានបង្កើនអនុភាពរួមគ្នាជាមួយផ្លេកបន្ទោរលាន់ឆ្វាចនិងសព្ទផ្គរលាន់គ្រាំ។ ភាពត្រជាក់ស្រេងគ្របដណ្តប់លើទិដ្ឋភាពស្ងាត់ជ្រងំនៃអាការរោគសើស្បែកនៃបន្ទប់រង់ចាំពិសេសសម្រាប់ប្រលានយន្តហោះ។

អ្នកស្រីកុលាបដែលបិទភ្នែកជិតឈឹងដកដង្ហើមធ្ងឹតធ្ងក់ដោយអាការតានតឹងពេញសារពាង្គកាយ។ប៉ូលិសវិទូនិយាយតិចៗទៅកាន់គាត់ដោយមានប៉ូលិសភ័ណនិងអ្នកកត់ត្រាឈរពីក្រោយផង៖

-អ្នកបង! លោកបងសារភាពអស់ហើយ តុលាការប្រហែលជាកោះហៅគាត់ក្នុងពេលមិនយូរជាងបីថ្ងៃទេ! បន្តិចទៀតអ្នកបងក៏នឹងឡើងយន្តហោះចេញទៅព្យាបាលនៅសិង្ហបុរីដែរ! អ្នកបងមានអ្វី ដែលមិនទាន់បាននិយាយប្រាប់ប៉ូលិសទេ?

អ្នកស្រីរូបល្អបណ្តាច់នៅសង្កាត់លេខមួយដែលរុំព័ទ្ធរាងកាយជិតជុំដោយស្បៃរុំរបួសគួរឲ្យសង្វេគហើយកាន់តែដង្ហក់ទៅតាមការផ្លាស់ប្តូរអារម្មណ៍របស់គាត់។ ដោយមានទឹកភ្នែកស្រក់មកតាមរោមភ្នែកដែលប្រឹងបិទផងគាត់និយាយមួយៗខ្សាវៗ៖

-អត់មានទេ!

យល់ច្បាស់ពីស្ថានភាពគាត់ វិទូងក់ក្បាលផ្ងក់ៗបន្លឺបន្ថែម៖

-បាន! ប៉ុន្តែសូមជូនដំណឹងថា ពាក្យសារភាពរបស់អ្នកបងមួយចំនួនមានទាក់ទងដល់សំណុំរឿងទាំងមូល អ្នកបងមានចំណែកទាក់ទងនឹងការប្រើប្រាស់សារធាតុញៀននិងកាត់ហ្វ្រាំងឡានប៉ងធ្វើឃាតប្អូនថ្លៃស្រី អ្នកបងមានជំងឺធ្ងន់ទើបតុលាការអនុញ្ញាតឲ្យចេញទៅព្យាបាលសិន តែមិនមែនមានន័យថាអ្នកបងបានរួចពិរុទ្ធនោះទេ!

ស្ត្រីអ្នកជំងឺសើចស្ងួតកំដរបបូរមាត់ស្លេកស្លាំងគ្មានឈាម គាត់បន្លឺតិចៗ៖

-មនុស្សស្រីម្នាក់ដែលរៀបការមិនដូចបំណង មានអីខុសពីនៅក្នុងនរកទៅហើយ! តើមានពិរុទ្ធណាទៀតដែលធ្ងន់ធ្ងរជាងហ្នឹង!?

គាត់នៅស្ងៀមលែងស្តីក្រោមកែវភ្នែកសញ្ជឹងគិតរបស់ប៉ូលិសទាំងបី។ ពេលវេលាស្ងប់ស្ងាត់រំលងទៅបានពីរបីដង្ហើមប៉ូលិសភ័ណគ្រហែមយកសំឡេងរួចពោលសួរ៖

-អ្នកស្រីកុលាប! បើអាពាហ៍ពិពាហ៍ជាមួយអ្នកមានម្នាក់ដូចជាចូលទៅរស់នៅក្នុងឋាននរក កាលណោះអ្នកស្រីទទួលយកអាពាហ៍ពិពាហ៍នេះធ្វើអ្វី?

ស្ត្រីនោះនៅស្ងៀមឈឹងមិនខ្វីឆ្លើយគិតពីបិទភ្នែកនិងម្តងម្កាលជ្រួញចិញ្ចើមដោយការឈឺចាប់មិនដឹងថាជាការឈឺចាប់ផ្លូវចិត្តឬផ្លូវកាយឲ្យ ប្រាកដឡើយព្រោះស្ថានភាពគាត់គឺមានទាំងពីរ។ ភ័ណនិយាយបន្ត៖

-ការច្រណែនប្រចណ្ឌជារឿងធម្មតា តែអ្នកនាងភីណាជាភាគីទីបីដែលមិនដឹងរឿងហេតុអ្វីចាំបាច់ឲ្យទូលថ្មបាក់ពីបរាជ័យនៃអាពាហ៍ពិពាហ៍របស់ពួកអ្នក?

អ្នកស្រីកុលាបបើកភ្នែកភ្លែត។ កំហឹងក្នុងពន្លឺភ្នែករបស់គាត់បង្ហាញថាឈ្មោះភីណាបានធ្វើឲ្យគាត់រើកកាយការឈឺចាប់ត្រឡប់មកវិញ។ សូម្បីតែវិទូក៏មិននឹកស្មានដល់ថា គូដណ្តឹងខ្លួនជាមនុស្សដែលស្ត្រីអភិជនមានគំនុំជ្រៅដល់ម្លឹងទេ។ អ្នកកំលោះបើកភ្នែកគ្រលួងសម្លឹងមើលប្រតិកម្មនៃស្ត្រីដែលមានពិរុទ្ធ។ អ្នកស្រីកុលាបខាំមាត់និយាយផ្ទូងហាក់ប្រមូលបានកម្លាំងថ្មីពីណាមកមិនដឹង៖

-ឃើញមុខស្រីនោះខ្ញុំក៏នឹកដល់ម្តាយរបស់វា!

គាត់មិននិយាយបន្តទៀតទេតែភាពចងអាឃាតបានបង្ហាញចេញលើផ្ទៃមុខគាត់ស្រេចទៅហើយ។វិទូសង្ងើញសួរ៖

-កោតតែអ្នកបងធ្វើអញ្ចឹងនាំឲ្យផ្លូវចិត្តខ្លួនមានបញ្ហា! ម្តាយភីណាស្លាប់យូរណាស់ហើយ! ហេតុអ្វីអ្នកបងចាំបាច់ត្រូវច្រណែនប្រចណ្ឌសូម្បីតែជាមួយមនុស្សដែលលែងមានជីវិតលើលោកនេះ?អ្នកបងយល់ថាអ្នកជុំវិញខ្លួនមានបញ្ហាឬខ្លួនឯងផ្ទាល់មានរោគចិត្ត?

អ្នកស្រីកុលាបសើចក្អាកក្អាយ។ ជាសំណើចដែលមិនធ្លាប់កើតមានចំពោះស្ត្រីអម្បូរអភិជនដែលគ្រប់គ្នាគោរពឱនលំទោន។ វិទូនិយាយតិចៗដោយមួហ្មង៖

-ខ្ញុំយល់ថា ផ្លូវចិត្តអ្នកបងមានបញ្ហាច្រើនជាង! ភីណាមិនដឹងរឿង ហើយជាក្មេងជំនាន់ក្រោយ អ្នកបងចង់សម្លាប់គ្នាម្តងហើយម្តងទៀត! បើតាំងខ្លួនជាចាស់ទុំរបស់គេ ជាបងថ្លៃរបស់គេ អ្នកបងសមទេដែលធ្វើរឿងស្មោកគ្រោកអស់នេះទៅលើប្អូនថ្លៃខ្លួនឯង? នាងខុសអី? ទីបំផុតរុញប្តីឲ្យទាល់ច្រក ហើយគាត់វាយបកមកវិញ។ ឥឡូវគ្រួសារវិនាសហិនហោច អ្នកបងក៏ត្រូវទទួលខុសត្រូវ!អ្នកបងត្រូវតែសងយុត្តិធម៌ឲ្យភីណា!

អ្នកស្រីកុលាបគំហកញ័រមាត់ទទ្រើក៖

-ចុះខ្ញុំ? អ្នកណារកយុត្តិធម៌ឲ្យខ្ញុំ? ខ្ញុំរៀបការជាមួយមនុស្សប្រុសម្នាក់ដែលគ្មានលទ្ធភាពសូម្បីបង្កើតកូន! ទីបំផុត គេប្រគល់អ្វីៗទៅឲ្យកូនមុនរបស់គេជាមួយសហាយចាស់! ចុះជីវិតខ្ញុំ? អ្នកណាសងអនាគតខ្ញុំដែលត្រូវគេបំផ្លាញនោះ?

ភ័ណតបភ្លែត៖

-លោកកុសលជាមួយម្តាយចុងគាត់អាចបង្កើតបានភីណារឿងអីថាគាត់មានបញ្ហាបន្តពូជ? រឿងនេះអាចថាមកពីអ្នកស្រីខ្លួនឯងដែលមិនទាន់មានកូនហើយកើតចិត្តច្រណែនរហូតដល់ឆ្កួតវង្វេងក្នុងទោសៈ?

អ្នកស្រីកុលាបស្រែកវិញ៖

-លោកប៉ូលិសអស់ឯងមានឆ្ងល់ថាហេតុអីកញ្ញាស់នោះស្រលាញ់កូនឥតខាន់ស្លារបស់វាដល់ម្លឹង?

គ្មានអ្នកណាតបទេព្រោះពួកគេកំពុងផ្តោតអារម្មណ៍ស្តាប់។ ស្ត្រីនោះបន្តដោយទឹកភ្នែក៖

-ព្រោះវាដឹងច្បាស់ថាមួយជីវិតនេះ វាគ្មានលទ្ធភាពមានកូនជាមួយស្រីណាទៀតទេ!

វិទូថ្លោះទឹកមុខក្នុងពេលត្រចៀកលឺស្ត្រីនិយាយលាយសំណោកគគ្រូក៖

-តើវាឆ្កួតឬខ្ញុំឆ្កួតដែលវាហ៊ានបំពេញចិត្តសហាយមុនរបស់វាដោយគ្រាវខ្លួនឯង?

វិទូទ្រេតទ្រោតព្រោះទន់ជើងក្នុងពេលដៃភ័ណចំហមាត់ធ្លុងព្រោះតក់ស្លុត។ អ្នកស្រីកុលាបនិយាយបន្តទាំងរន្ធត់៖

-វាសហាយជាមួយម្ដាយចុងរហូតដល់សន្យាជាមួយស្រីចង្រៃនោះថាមិនប៉ះពាល់ស្រីណាទៀតទេក្នុងជាតិនេះ ចុះក្រោយមកវារៀបការជាមួយខ្ញុំធ្វើអី? វាបំផ្លាញអនាគតខ្ញុំទាំងស្រុងដឹងទេ? មានអ្នកណាដឹងទេ? មានអ្នកណាខ្លះរកយុត្តិធម៌ឲ្យខ្ញុំ? ខ្ញុំក្លាយជាមនុស្សគេរើសមកសម្រាប់លុបបំបាត់ពាក្យចចាមអារ៉ាមក្នុងសង្គមជាន់ខ្ពស់របស់គេ ហើយទីបំផុតស្អីក៏ខ្ញុំគ្មាន? ចាកចេញក៏មិនបានហើយមរតកមាន១០ភាគរយ អ្នកណារកយុត្តិធម៌ឲ្យខ្ញុំ? អ្ហា? ឆ្លើយមក? អស់លោកមន្ត្រីយុត្តិធម៌?

វិទូអត់អ្វីនិយាយទៀតទេ។ នាយឈរផ្អែកខ្នងទៅនឹងជញ្ជាំងបន្ទប់ ល្មមពេលលឺសំឡេងភ័ណនិយាយម្ដង៖

-បើអ្នកស្រីស្អប់លោកកុសលហេតុអ្វីបង្វែរគោលដៅធ្វើឃាតទៅរកកូនស្រីគាត់ទៅវិញ?

ស្ត្រីក្មេងដែលស្ទើរតែសល់ដង្ហើមចង្រិតនិយាយតបទាំងសើចស្ងួត៖

-សម្លាប់មនុស្សដែលវាស្រលាញ់បំផុត ទើបអាចឲ្យវាដឹងថា អ្វីទៅជាការឈឺចាប់!

វិទូបោះជំហានចេញឈប់ស្ដាប់ព្រោះមិនអាចទទួលយកការពិតទាំងអស់នេះបានតទៅទៀត។ អ្នកកំលោះដឹងថាព្រោះតែគំនុំអាចជំរុញឲ្យមនុស្សគិតឃើញរឿងឆ្កួតលីលាជាច្រើនរាប់ទាំងអំពើស្មោកគ្រោកនានាផង។

ស្ត្រីនោះត្រូវបានបញ្ជូនចាកចេញទៅ តែភាពក្ដុកក្ដួលនៅសេសសល់ធ្ងន់ក្ដុកក្នុងចិត្តប៉ូលិសនានា។តាមពិតនៅពីក្រោយសំណុំរឿងឧក្រិដ្ឋតែងតែបង្កប់នូវដើមចមគួរឲ្យសង្វេគ ប៉ុន្តែករណីរបស់អ្នកស្រីកុលាបជាករណីដែលគ្មានអ្នកណាម្នាក់ជឿថានៅមានលើលោកនេះទេ។

គ្រាវខ្លួនឯងដើម្បីស្នេហ៍ស្មោះ? បើអញ្ចឹងក្រោយមកគាត់ការប្រពន្ធធ្វើអី? គាត់ដឹងថាខ្លួនឯងមិនអាចមានកូនណាក្រៅពីភីណាទៀតក៏ផ្ដល់អ្វីៗទាំងអស់ទៅឲ្យនាង ហេតុអ្វីគាត់មិនគិតពីស្ត្រីក្មេងម្នាក់ដែលមានរូបល្អបណ្ដាច់ត្រូវបញ្ចប់អនាគតទាំងស្រុងដោយសារគាត់?

-តាមពិតអ្នកស្រីកុលាបក៏គួរឲ្យអាណិតដែរហ្ន៎!

សំឡេងប៉ូលិសកត់ត្រានិយាយហើយដើរហួសកាត់ទៅបាត់សល់តែវិទូនៅឈរទ្រឹងម្នាក់ឯង។ ពេលនោះភ័ណដកដង្ហើមធំហើយនិយាយតិចៗពីក្រោយខ្នងគេ៖

-មនុស្សយើងព្រោះតែឆ្កួតស្នេហ៍ រឿងឡប់អញ្ជឹងក៏ធ្វើកើតដែរ? គ្រាវ? អារំបល់យក៍! បើអញ្ជឹងវាការគេមកធ្វើអី!

វិទូឥតនិយាយអ្វីចេញស្ដីសូម្បីតែមួយម៉ាត់។ អ្នកកំលោះនៅស្ងៀមតែចិត្តកំពុងតែវិលវល់។ សំឡេងប៉ូលិសភ័ណលាន់មកបន្ថែម៖

-ធ្វើអ្នកអនុវត្តច្បាប់មិនបាច់យករឿងគេមកគិតពេកទេនាំតែកើតរោគចិត្តអត់អំពើ! ចោរខ្លះលួចគេដើម្បីចិញ្ចឹមម៉ែឪចាស់! ចោរខ្លះប្លន់គេព្រោះកូននៅផ្ទះឈឺធ្ងន់គ្មានលុយមើល! ចោរខ្លះធ្វើអាក្រក់ព្រោះបរិយាកាសមិនអំណោយផលឲ្យគេក្លាយជាមនុស្សល្អបាន! ទាំងអស់នេះសុទ្ធតែជាសោកនាដកម្មភ្នែកស្រស់ដែលប៉ូលិសត្រូវជួបត្រូវលឺព្រឹកល្ងាច! សរុបមក ធ្វើតាមច្បាប់ ជាកាតព្វកិច្ចរបស់យើង! តោះទៅរកអីដាក់ពោះព្រោះឯងត្រូវឆ្លងកាត់គូដណ្ដឹងឯងមួយដំណាក់ទៀត! ត្រូវសន្សំកម្លាំងទប់ទល់សិនទៅ!

តើយុត្តិធម៌និងការអនុវត្តន៍ច្បាប់ពិតជាត្រូវប្រកួតយ៉ាងតឹងតែងជាមួយមនោសញ្ចេតនាដូចមានពាក្យថាយល់ញាតិឃ្លាតច្បាប់មែនឬ? តាមពិតវិទូក៏ដឹងដែរថា ប្រសិនបើសំណុំរឿងម៉ោង១២អធ្រាត្រនៅសង្កាត់លេខមួយត្រូវបានបំបែក លទ្ធផលចុងក្រោយនឹងមានការប្រេះឆាដ៏ធំដែលដំបូងបង្អស់អ្នកគិតថាត្រឹមរវាងប្ដីប្រពន្ធលោកកុសល តែការពិតចុងក្រោយបង្អស់ដែលត្រូវបានរកឃើញមិនត្រឹមតែបានធ្វើឲ្យអ្នកកំលោះស្រងល់ចំពោះការពិតដ៏ឈឺចាប់របស់អ្នកស្រីកុលាបដ៏ក្មេងខ្ចីទេ តែក៏ឲ្យអ្នកកំលោះដឹងមុនជាស្រេចដែរថា ចំណងស្នេហ៍តាំងពីកុមារភាពរបស់អ្នកកំលោះនិងធីតាក្មេងខ្ចី១០០ភាគរយនឹងត្រូវកាត់ផ្ដាច់។

ដូចជាពេលនេះ....ពេលដែលអ្នកកំលោះត្រឡប់មករកនាងនៅផ្ទះ....

ភីណាខាំមាត់ងាកមិនព្រមមើលវិទូ នាងយំទាល់តែរីងទឹកភ្នែកហើយស្រវាកញ្ចក់កាបូបចាកចេញក្នុងពេលវ៉ាលិសត្រូវបានមីងអួនអូសចេញទៅមុនទាំងទឹកមុខស្លេកស្លាំង។ វិទូស្រវាចាប់បើកដៃស្រីមកវិញ ប៉ុន្តែនាងមិនងាកមកមើលនាយឡើយ ស្រីក្មេងនិយាយដោយយំទន់ខ្លួន៖

-បងឯងលែងដៃខ្ញុំ!

វិទូនិយាយតិចៗពីលើស្នូរគ្រាប់ភ្លៀង៖

-ចាំភ្លៀងរាំងសិនសឹមទៅ!

ភីណាកែវភ្នែកពេញដោយទុក្ខសោកនាងរុញដៃនាយចេញតិចៗហើយដើរតម្រង់រកមាត់ទ្វារបន្ទប់ ។សម្លេងវិទូលាន់មកស្រាលៗ៖

-បងអត់បានធ្វើអីខុសទេភីណា! គឺលោកបងធ្វើរឿងខុសច្បាប់ដោយខ្លួនឯង!

នារីអភិជនស្រក់ទឹកភ្នែកច្រោក នាងងាកក្រោយសម្លឹងគូដណ្តឹង នាងប្រឹង ណាស់ទើបនិយាយបានដោយអណ្តឹតអណ្តក៖

-តែបងឯងដឹងហើយមែនអត់ ថាគាត់ធ្វើអញ្ចឹងដើម្បីការពារខ្ញុំ! បងឯងប្តឹងគេចាប់គាត់! បងឯងមានគិតដល់ខ្ញុំអត់?

វិទូខំចូលទៅជិតហើយពន្យល់នាងពីក្រោយខ្នង៖

-ឧក្រិដ្ឋកម្មធំដល់ម្លឹងយកដៃបាំងមេឃបាំងមិនជិតទេភីណា? ច្បាប់មានសម្រាប់អនុវត្ត អ្នកណាធ្វើអ្នកនោះទទួល!

-ត្រូវហើយអ្នកណាធ្វើអ្នកនោះទទួល!

នាងនិយាយតិចៗដោយមិនបែរក្រោយតែវិទូដឹងថានាងកំពុងឈឺចាប់ណាស់តាមរយៈសំឡេងរអាក់រអួលរបស់នាង។អ្នកហើបមាត់មិនរួច លឺតែសំឡេងនាងនិយាយបន្ត៖

-ហើយខ្ញុំក៏អស់មានអ្នកណាទៀតដែរ!

នាងចាកចេញទៅដោយមានអ្នកបម្រើប្រុសស្រីនៅរង់ចាំជាស្រេច។វិទូឃាត់នាង ក៏រឹតតែមិនអាចប្រាប់នាងឲ្យអស់សេចក្តីពីការពិតដ៏ស្មុគស្មាញនិងគួរឲ្យរន្ធត់ដែលអ្នកកំលោះទើបតែដឹងពីអ្នកស្រីកុលាបទេព្រោះនាងជាផ្ទាំងសំពត់សដែលត្រូវឈឺចាប់គ្រប់គ្រាន់ហើយដោយសាររឿងមនុស្សជំនាន់មុន។ ដូច្នេះអ្នកកំលោះមានតែបណ្តោយឲ្យនាងគិតទៅតាមអ្វីដែលនាងយល់ថាត្រូវ។

នៅ Apartmentបឹងកេងកងអ្នកកំលោះបានសន្យានឹងនាងថា អ្នកកំលោះនឹងស្វែងរកយុត្តិធម៌ឲ្យស្រីស្អាតប៉ុន្តែបងប្រុសនាងដែលជាឳពុកលួចលាក់របស់នាងតក់ក្រហល់កាត់ទោសសត្រូវដោយខ្លួនឯងធ្វើឲ្យដំណើររឿងទៅជានាគវាត់កន្ទុយដែលគាត់ខ្លួនឯងត្រូវទទួលខុសត្រូវធ្ងន់ចំពោះមុខច្បាប់។អ្នកស្រីកុលាបត្រូវពិការមួយជីវិតដោយសារធាតុគីមីពុល

ចំណែកភីណាក្រោយពេលបងប្រុសចាញ់ក្ដីជាចុងក្រោយនៅសាលាឧទ្ធរណ៍ហើយត្រូវទទួលទោសជាប់ពន្ធនាគារ នាងបានចាកចេញពីប្រទេសទៅបន្តការសិក្សាសហរដ្ឋអាមេរិក។

ប៉ូលិសកម្សត់ស្នេហ៍នៅតែស្មោះត្រង់ចាំនាងរហូតដល់៣ឆ្នាំក្រោយមកនាយបានទទួលដំណឹងថាភីណាបានរៀបការជាមួយមេធាវីខ្មែរអាមេរិកម្នាក់ដែលដំណឹងនេះបានបញ្ចប់ទាំងស្រុងនូវចំណងស្នេហ៍របស់ពួកគេនិងក្ដីសង្ឃឹមរបស់នាយ។

រិទ្ធផ្លាស់ទៅក្រុងព្រះសីហនុដោយផ្ដោតអារម្មណ៍តែលើការងាររហូតដល់បំបែកបានសំណុំរឿងមួយចំនួនរួមមានករណីឃាតកម្មនៅស្ទូឌីយោលេខ៧ដ៏កក្រើកនោះផង។ នៅឆ្នាំ២០១២គេបានទទួលការតែងតាំងឋានន្តរសក្តិថ្មីជាឧត្តមសេនីយ៍និងផ្លាស់មកនៅបម្រើការងារនៅនាយកដ្ឋានអន្តោប្រវេសន៍ជាទីដែលគេបានជួបភីណាសាជាថ្មីបន្ទាប់ពីនាងបានត្រឡប់មកកាន់ស្រុកកំណើតវិញជាមួយស្វាមី។ ការជួបគ្នាឡើងវិញបន្ទាប់ពីពេលជាង៤ឆ្នាំរវាងអតីតគូស្នេហ៍ដែលម្នាក់ជាកំលោះនិងម្នាក់ទៀតជាភរិយានៃមេធាវីអន្តរជាតិដ៏ល្បីឈ្មោះបានបង្កើតទៅជាសាច់រឿងប្រលោមលោកស៊ើបអង្កេតថ្មីសន្លាងមួយផ្នែកបច្ចេកវិទ្យាស៊ីជម្រៅនិងវិបត្តិចាក់ស្រេះជុំវិញករណីឃាតកម្មក្ដៅគគុកមានឈ្មោះថា "សំណុំឯកសារZ22″។

តើចង់អានទេ?

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមយោបល់ទិតៀនស្ថាបនាពិសេសការគាំទ្រ និងតាមដានតាំងពីដើមរហូតដល់ចប់ ៕

**ចប់**

